# ព្រះជាម្ចាស់ជាអ្នកបកស្រាយ សម្រាប់ព្រះអង្គផ្ទាល់

ព្រះវរបិតាដែលនៅស្ថានសួគ៌ ព្រះបន្ទូលមកពីទ្រង់មានន័យជាងនរណា
ទាំងអស់ គ្រប់សម័យទាំងអស់ ព្រោះមនុស្សកំពុងរង់ចាំដើម្បីជួបទ្រង់។
យើងអរព្រះគុណ ទ្រង់ព្រោះមានអ្នករំពឹងគិតពួកគេរង់ចាំអ្វីដែលនឹងកើតឡើង។
ហើយ ពេលមនុស្ស កំពុងស្រេកឃ្លានសម្រាប់សេចក្តី ដែលជាការត្រាស់ហៅ
យ៉ាងជ្រៅចូលទៅកាន់ ជម្រៅមួយ ហើយក៏មានភាពជ្រាលជ្រៅនៃការត្រាស់ហៅ
ផងដែរ។ ហើយ នេះជា ហេតុដែលពួកទូលបង្គំនៅទីនេះនៅយប់នេះ ពីព្រោះ
ដោយសារតែចិត្តបម្រើទាំង នេះ និងមនុស្សទាំងនេះ ដែលត្រូវបានត្រាស់ហៅចូល
មកប្រជុំគ្នាដើម្បីទូលសុំទ្រង់ សម្រាប់ការសព្វព្រះទ័យ និងព្រះពរ ដោយជឿថា
ព្រះអង្គនឹងប្រោសអ្នកជំងឺ និង សង្គ្រោះអ្នកបាត់បង់ និងបើកសម្ដែងព្រះបន្ទូល
របស់ទ្រង់។

2 ហើយទូលបង្គំអធិស្ឋាន ព្រះវរបិតានៅស្ថានសួគ៌អើយ សូមទ្រង់ទទួលការ
នេះពេលដែលទូលបង្គំរង់ចាំទ្រង់ដោយបន្ទាបខ្លួន ពីមួយយប់ទៅមួយយប់។
សូម ឱ្យមាន—មានការចាក់ព្រះវិញ្ញាណបរិសុទ្ធ ហើយសូមឱ្យមនុស្ស មានភាព
ងងឹតចំពោះស្ថានភាពជុំវិញហើយភ្លឺនៅចំពោះព្រះជាម្ចាស់វិញ។ សូមឱ្យ មានការ
ស្រែក ដង្ហោយដ៏ខ្លាំងក្នុងចំណោមមនុស្ស ស្រេកឃ្លានរកព្រះជាម្ចាស់ រហូត
មានការផុសផុលទូទាំង តំបន់នេះដើម្បីទទួលការសណ្ដោសមេត្តាពីព្រះ និង—និង
ព្រះវិញ្ញាណបរិសុទ្ធប្រោសអ្នកជំងឺ ធ្វើឱ្យអ្នកខ្វិនដើរបាន និងប្រោសអ្នកស្លាប់ឱ្យ
រស់ ហើយសូមទ្រង់ទទួលយកសេចក្តីទាំងនេះដែលបានសន្យាតាមព្រះបន្ទូល
របស់ទ្រង់។

3 សូមព្រះយេស៊ូគ្រិស្ដយាងមក ហើយបំពេញសេចក្ដីសន្យារបស់ទ្រង់។
សូមយាងមកកាន់ពួកទូលបង្គំយប់នេះ។ ទូលបង្គំជឿថាទ្រង់នៅដូចកាលពី
ថ្ងៃម្សិលមិញ ថ្ងៃនេះ និង រៀងរហូតទៅ ដែលសេចក្ដីសន្យារបស់ទ្រង់មិន
ឥតការឡើយ។ ទាំងផ្ទៃមេឃនិងផែនដីនឹងបាត់បង់ទៅ តែព្រះបន្ទូលរបស់ទ្រង់
មិនបរាជ័យឡើយ។ សូមឱ្យការយល់ដឹងរបស់ទូលបង្គំបានបើកឡើង។ សូម

ឱ្យព្រះវិញ្ញាណបរិសុទ្ធយាងមក និងតាំងលើដីទំនេរ។ សូមឱ្យការយល់ដឹងរបស់ទូលបង្គំបានបើកឡើងចំពោះព្រះវិញ្ញាណបរិសុទ្ធ និងឫទ្ធិអំណាចរបស់ព្រះជាម្ចាស់នៅយប់នេះដែលទ្រង់ នឹងអាចបើកសម្តែងឱ្យឃើញសេចក្តីសន្យារបស់ទ្រង់តាមរយៈទូលបង្គំរាល់គ្នា។ ហើយទូលបង្គំទូលសូមដោយព្រះនាមព្រះយេស៊ូ។ អាម៉ែន

4 ឥឡូវនេះ យប់នេះ អ្នកដែលមើលអត្ថបទ សូមបើកទៅកាន់គម្ពីរពេត្រុសខ្សែរទីពីរ ហើយចាប់ផ្តើមពីខទី១៥ ដូចដែលយើងបាននិយាយខគម្ពីរអម្បាញ់មិញ។

*មួយទៀតខ្ញុំនឹងខំប្រឹងរំឭករាល់ពេលវេលា ឲ្យអ្នករាល់គ្នាបាននឹកចាំពីសេចក្តីទាំងនេះក្រោយដែលខ្ញុំទៅបាត់ដែរ។ បន្ទាល់អំពីសិរីរុងរឿងរបស់ព្រះយេស៊ូវ។*

*ដ្បិតដែលយើងខ្ញុំបានឲ្យអ្នករាល់គ្នាស្គាល់ដល់ព្រះចេស្ដានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង និងដំណើរដែលទ្រង់យាងមក នោះមិនមែនតាមរឿងព្រេងប្រឌិតដោយដំរិះនោះទេ គឺយើងខ្ញុំជាស្មរបន្ទាល់ ដែលបានឃើញឫទ្ធានុភាពរបស់ទ្រង់ជាក់នឹងភ្នែកវិញ។*

5 ខ្ញុំចូលចិត្តពាក្យ "ជាក់នឹងភ្នែក។" មិនមែនរឿងព្រេងប្រឌិត។ យើងជាស្មរបន្ទាល់ពីអ្វីដែលយើងកំពុងនិយាយ។

*ដ្បិតទ្រង់បានល្បីព្រះនាម និងសិរីល្អពីព្រះដ៏ជាព្រះវរបិតា ក្នុងកាលដែលមានឮសំឡេងពីសិរីល្អដ៏ប្រសើរឧត្តម មានព្រះបន្ទូលមកទ្រង់ថា នេះជាកូនស្ងួនភ្ងាអញ ជាទីគាប់ចិត្តអញណាស់។*

*យើងខ្ញុំបានឮសំឡេងនោះមកពីលើមេឃ ក្នុងកាលដែលនៅលើភ្នំបរិសុទ្ធជាមួយនឹងទ្រង់ ។*

*ហើយយើងខ្ញុំមានពាក្យទំនាយដ៏ពិតជាង ដែលគួរឲ្យអ្នករាល់គ្នាយកចិត្តទុកដាក់តាម ដូចជាតាមចង្កៀងដែលភ្លឺក្នុង...ទីងងឹត ទាល់តែថ្ងៃភ្លឺឡើង ហើយផ្កាយព្រឹករះឡើងក្នុងចិត្តអ្នក រាល់គ្នា:*

*ដោយដឹងសេចក្តីនេះជាមុនដំបូងថា គ្មានពាក្យទំនាយណាក្នុងគម្ពីរដែលស្រាយបានតាមតែចិត្តនោះឡើយ ។*

*ដ្បិតសេចក្តីទំនាយមិនដែលមក ដោយបំណងចិត្តមនុស្សទេ*

*គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយដោយសារព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បណ្តាលវិញ។*

6 សូមឱ្យព្រះអម្ចាស់បន្ថែមព្រះពរទៅកាន់ អ្នកអានព្រះបន្ទូលព្រះអង្គ។ ឥឡូវខ្ញុំនឹងយកឃ្លានេះជាប្រធានបទគឺ: *ព្រះជាម្ចាស់ជាអ្នកបកស្រាយសម្រាប់ទ្រង់ផ្ទាល់។*

7 យើងកំពុងរស់នៅសម័យដែលច្របូកច្របល់។ យើងកំពុងតែរស់ក្នុងសម័យដែលមនុស្ស ប្រុសស្រីមិនដឹងថាត្រូវធ្វើអ្វី។ គ្រប់យ៉ាង វា—វាហាក់បីដូចជាចលាចល។ គ្រប់យ៉ាងហាក់បីដូចជា មានផ្លូវច្រើនដែលត្រូវសម្លឹងមើល។ វាគឺជាសាតាំង ដែលធ្វើការបែបនោះ។

8 ឥឡូវ ព្រះជាម្ចាស់មិនអាចជំនុំជម្រះ មនុស្សជាសុចរិត ដោយត្រឹមត្រូវទាល់តែមានក្បួនវិធីដើម្បីជំនុំជម្រះ។ ហើយព្រះគម្ពីរបានប្រាប់ថា ព្រះអង្គជំនុំជម្រះមនុស្សដោយ ព្រះយេស៊ូគ្រិស្ត ហើយ ព្រះយេស៊ូគ្រិស្តគឺជាព្រះបន្ទូល។ ក្នុងគម្ពីរសាវកយ៉ូហាន ជំពូក១ និយាយថា:

*កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។*

*ព្រះបន្ទូលក្លាយជាសាច់ឈាម ហើយរស់ក្នុងចំណោមយើង...*

9 ឥឡូវ គ្រប់ទាំងយើងទាំងអស់គ្នាមានសព្វថ្ងៃនេះ គឺជាលក្ខណៈសម្បត្តិរបស់ ទ្រង់។ ក្នុងព្រះជាម្ចាស់...ពីដំបូងព្រះអង្គមិនមែនត្រឹមតែជាព្រះនោះទេ ព្រះជាម្ចាស់ យើងបានហៅព្រះអង្គថា "អង្គដ៏នៅអស់កល្ប។" ព្រះអង្គមិនមែនជាព្រះ ពីព្រោះពាក្យ(ភាសាអង់គ្លេស)*ព្រះ* មានន័យថា "រូបអ្វីមួយដែលត្រូវបានថ្វាយបង្គំ" ឬ ថាគ្មានអ្វីដែលត្រូវថ្វាយបង្គំទ្រង់ឡើយ។ ដូច្នេះ ព្រះអង្គជាអង្គគង់នៅអស់កល្ប ជា—ជាប្រភពដើមនៃប្រាជ្ញាញាណលើសទាំងអស់។ ហើយព្រះប្រាជ្ញាញាណដែលលើសទាំងអស់នេះ មិនមែនជាអាតូម ម៉ូលីគុល ឬ មិនជាអ្វីទាំងអស់ គ្មានពន្លឺទីណាមួយ ផ្កាយ លោកខែ ឬ គ្មានអ្វីទាំងអស់។ ព្រះជាម្ចាស់អ្វីដែលយើងដឹងគឺព្រះអង្គជាព្រះ ជាព្រះវិញ្ញាណដែលនៅអស់កល្ប (មិនមានការចាប់ផ្តើម មិនមានការបញ្ចប់) ព្រះអង្គមានវត្តមានគង់នៅ។ ហើយ នៅក្នុងទ្រង់មានលក្ខណៈសម្បត្តិ: ជាលក្ខណៈសម្បត្តិដែលជាព្រះ រួចមានលក្ខណៈសម្បត្តិជា

ព្រះបិតា លក្ខណៈសម្បត្តិដែលជាព្រះបុត្រា លក្ខណៈសម្បត្តិដែលជាព្រះសង្គ្រោះ លក្ខណៈសម្បត្តិដែលជាអង្គប្រោសឱ្យជា។ រាល់លក្ខណៈសម្បត្តិទាំងនេះ គឺនៅក្នុងព្រះអង្គ។ ហើយឥឡូវ ព្រះអង្គ...សេចក្តីទាំងនេះបានត្រដាង ដោយព្រោះលក្ខណៈសម្បត្តិរបស់ទ្រង់បាននាំឱ្យមានការបើកសម្តែងឱ្យឃើញ។

10 អ្វីដែលខ្ញុំចង់និយាយពី*លក្ខណៈសម្បត្តិ*គឺជា"ព្រះតម្រិះ។" ហើយ—*ព្រះបន្ទូល* ជា "ព្រះតម្រិះដែលស្តែងចេញមក។" ហើយបន្ទាប់មកជាអ្វីដែលនៅក្នុងព្រះហឫទ័យត្រិះរិះរបស់ព្រះអង្គ។ ហើយពេលទ្រង់មានបន្ទូល "ចូរឱ្យមាន" ហើយវាក៏មាន។ "ចូរឱ្យមាន" នោះក៏មានមែន។

11 ហើយឥឡូវ ចូរចាំថា អ្នកជាគ្រីស្ទានគឺជាព្រះទ័យត្រិះរិះរបស់ព្រះអង្គ មុនផែនដីទៅទៀត។ ហើយអ្នកគឺជា ការបើកសម្តែងឱ្យឃើញនៃព្រះតម្រិះរបស់ទ្រង់។ មុននឹងកើតមានផែនដី គឺអ្នកនៅក្នុងព្រះគ្រិស្ត (អាម៉ែន) នៅក្នុងព្រះជាម្ចាស់តាំងពីដើមដំបូងមក។ ដែលបង្កើតជាអ្នក ហើយ អ្នកឃើញពីប្រធានបទរបស់ទ្រង់ទេ។ ហើយ សេចក្តីទាំងមូលគឺជាព្រះជាម្ចាស់ ព្រះអង្គផ្ទាល់ ធ្វើឱ្យអ្វីទាំងអស់ដែលប៉ះបាន ពិតស្តែង ដូច្នេះនឹងអាចគ្រប់គ្រងបាន ឃើញ និង—និងអ្វីផ្សេងទៀតជាដើម។ ហើយនោះហើយជាព្រះជាម្ចាស់ គ្រប់ការទាំងអស់។

12 រួចមនុស្សបាននិយាយ "ការបកស្រាយ..." ខ្ញុំបាននិយាយនៅទីនេះ មិនយូរកន្លងទេ កាលពីក្នុងការប្រជុំមួយ មនុស្សម្នាក់និយាយមកកាន់ខ្ញុំ គាត់និយាយ "បងប្រុស ប្រាណហាំ លោកមានការបកស្រាយខុស លោកបកស្រាយមិនត្រឹមត្រូវឡើយ។"

13 ឥឡូវ យើងពួ...ពួកគេទៅមេតូឌីស្ត ហើយនិយាយ "បាបទីស្ត បកស្រាយមិនត្រឹមត្រូវ។" អ្នកបាបទីស្តនិយាយ "អ្នកពេនទីកុស្តបកស្រាយមិនត្រឹមត្រូវ។" ពួកអ្នកពេនទីកុស្តនិយាយថា "ពួក—ពួកអ្នកវ៉ាន់ណេសបកស្រាយមិនត្រឹមត្រូវ។" ពួកអ្នកវ៉ាន់ណេសនិយាយថា "អ្នកអាស៊ិមប្លី បកស្រាយមិនត្រឹមត្រូវ។" ហើយម្នាក់ៗនៃពួកគេនិយាយថាអ្នកផ្សេងមិនត្រឹមត្រូវ។

14 ព្រះជាម្ចាស់ជាអ្នកបកស្រាយសម្រាប់ទ្រង់ផ្ទាល់! ព្រះអង្គមិនត្រូវការនរណាបកស្រាយសម្រាប់ព្រះអង្គឡើយ។ ព្រះអង្គធ្វើការបកស្រាយសម្រាប់ព្រះអង្គផ្ទាល់។ នរណាជាមនុស្សដែលអាចបកស្រាយពីព្រះជាម្ចាស់បាន? ព្រះជាម្ចាស់ជាអង្គបកស្រាយសម្រាប់ទ្រង់ផ្ទាល់។

15 ឥឡូវ ពេត្រុសនិយាយត្រង់ចំណុចនេះ យើងឃើញថាពីដំបូងពេល ព្រះជាម្ចាស់មានបន្ទូល "ចូរមានពន្លឺ" នោះក៏មានពន្លឺ នោះគឺជាការបកស្រាយសម្រាប់ការនោះឯង។ ពេលព្រះជាម្ចាស់មានបន្ទូលពីអ្វី ហើយ វាក៏បើកសម្តែងចេញមក ដូច្នេះហើយ ការបកស្រាយរបស់ព្រះជាម្ចាស់ថា ជាព្រះបន្ទូលរបស់ទ្រង់នោះ គឺត្រឹមត្រូវ។ ឃើញទេ?ពេលទ្រង់មានបន្ទូល "ចូរមានពន្លឺ" នោះគឺមាននៅក្នុងព្រះតម្រិះទ្រង់ជាមុនថាពន្លឺនោះជាបែបណា។ ពេលព្រះអង្គមានបន្ទូល "ចូរមានពន្លឺ" ពន្លឺក៏រីកសាយនៅលើផ្ទៃមេឃ នោះគឺជាការបកស្រាយ។ គ្មាននរណាបកស្រាយការនោះឡើយ ព្រោះព្រះជាម្ចាស់មានបន្ទូល ហើយ វាក៏កើតមាន។ ពេលព្រះជាម្ចាស់មានបន្ទូល វាក៏បើកសម្តែងឡើងមែន នោះជាការបកស្រាយពីព្រះបន្ទូល។ ហេតុអ្វីបាន ជាមនុស្សមិនអាចឃើញសេចក្តីនោះ? ហេតុអ្វីមនុស្សមិនឃើញការនោះ?

16 នៅពេលព្រះធ្វើការសន្យា ហើយព្រះអង្គមានបន្ទូល...កាល—កាលដើមដំបូងនៅលោកុប្បត្តិ ទ្រង់ដាក់ព្រះបន្ទូលទៅតាមសម័យកាលដែលវាបានតមកពីដើមដំបូងរហូតដល់ចុងបញ្ចប់។ ហើយ តមកសម័យនេះ ពិភពនៃក្រុមជំនុំបានមានសេចក្តីទាំងនេះបានលាយចូលនឹងវប្បធម៌ប្រពៃណី និង អ្វីផ្សេងទៀតហើយព្រះជាម្ចាស់តែងតែបញ្ជូនរូបភាព តាមរយៈ សញ្ញាចាស់និងសញ្ញាថ្មី ព្យាការី! ហើយព្រះបន្ទូលរបស់ព្រះ បានមកដល់ពួកព្យាការី។ តើវាអាចមកបានដោយរបៀបណា? វាបានបើកសម្តែងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ការបើកសម្តែងរបស់ព្រះជាម្ចាស់ បង្ហាញប្រាប់ថាតើវាត្រូវឬខុស។ គ្មាននរណាម្នាក់អាចបកស្រាយឡើយ ព្រះបន្ទូលនឹងបកស្រាយខ្លួនឯង។ ព្រះជាម្ចាស់មានបន្ទូលសន្យា ហើយវាក៏កើតមាន!

17 តើវាមានអ្វីល្អនៅពេលដែល និយាយពីអ្វីមួយផ្សេងអំពីវានោះ? តើនរណាដែលជាមនុស្សបាបព្យាយាមនិយាយ (ពេលព្រះជាម្ចាស់ធ្វើការសន្យានោះព្រះអង្គនឹងធ្វើ) នោះ ជាការបកស្រាយខុសឬ? នោះគឺជាព្រះជាម្ចាស់ផ្ទាល់ដែល ធ្វើការបកស្រាយសម្រាប់ព្រះអង្គផ្ទាល់។ ព្រះអង្គមិនត្រូវការនរណាបកស្រាយសម្រាប់ទ្រង់ឡើយ។ ព្រះអង្គបកស្រាយដោយទ្រង់ផ្ទាល់ដោយការបើកសម្តែងឱ្យឃើញ អ្វីដែលព្រះអង្គបានសន្យាថាព្រះអង្គនឹងធ្វើ។

18 អូ ប្រសិនបើក្រុមជំនុំអាចឃើញការនោះ និងឃើញសេចក្តីសន្យាដែលតាំងសម្រាប់សម័យកាលនីមួយៗ! សម័យកាលផ្សេងទៀត ព្រះជាម្ចាស់បានបញ្ជូនរូបភាព (បន្តចុះមកសម័យកាលក្រុមជំនុំទី៧) និងបានបើកបង្ហាញគ្រប់យ៉ាងដែលព្រះអង្គសន្យាថានឹងធ្វើ។ អ្វីគ្រប់យ៉ាង គ្មានអ្វីដែលនៅសល់មិនបានធ្វើឡើយ។ ជាការពិត! អ្វីដែលទ្រង់មានបន្ទូល ព្រះអង្គនឹងធ្វើ ដូចទ្រង់ធ្លាប់បានធ្វើ។

19 ព្រោះពេលព្រះជាម្ចាស់មានបន្ទូល ត្រឡប់ទៅអេសាយ ទ្រង់មានបន្ទូលថា "ស្រីក្រមុំព្រហ្មចារី នឹងមានផ្ទៃពោះ" ហើយនាងក៏មានផ្ទៃពោះមែន។ ឥឡូវ នរណា—នរណាអាចបកស្រាយសេចក្តីនេះបាន? ព្រះជាម្ចាស់បានធ្វើការបកស្រាយ។ ទ្រង់មានបន្ទូល "ស្រីព្រហ្មចារីនឹងមានគភ៌" នាងក៏មាន។ ឥឡូវតើអ្នក…អ្នកមិនអាច…គ្មានអ្វីអាចនិយាយពីការនោះឡើយ ព្រោះព្រះជាម្ចាស់មានបន្ទូលថានាងនឹងមាន ហើយ វាក៏កើតមានពិត។ ប៉ុន្តែក្រុមជំនុំ ងងឹតពេកដែលមិន អាចមើលឃើញបាន។ ឃើញទេ ពួកគេមានគំនិតផ្ទាល់សម្រាប់សេចក្តីនោះ។ វាខុសពី—ខុសពីអ្វីដែលពួកគេរំពឹងទុក។

20 លោកពេត្រុសនៅត្រង់ចំនុចនេះគឺសំដៅទៅក្រោយវិញ គាត់និយាយ "ព្រះជាម្ចាស់បើកសម្តែងពីព្រះគ្រិស្តដោយព្រះបន្ទូលទ្រង់ព្រះអង្គមានបន្ទូល 'នេះកូនជាទីស្រលាញ់របស់យើង។'" អ្នកជឿទាំងនេះឈរនៅទីនោះ។ ហើយព្រះគ្រិស្តគឺជាការបើកសម្តែងរបស់ព្រះជាម្ចាស់។ ព្រះអង្គតែងបើកសម្តែងពីព្រះគ្រិស្តដោយព្រះបន្ទូលព្រះអង្គព្រោះព្រះគ្រិស្តជាព្រះបន្ទូល។ ព្រះអង្គតែងសម្តែងឱ្យឃើញជានិច្ច។

21 ពេលព្រះអង្គមានបន្ទូល…នៅសម័យណូអេ ព្រះគ្រិស្តស្ថិតនៅក្នុងណូអេ។ តើអ្នកជឿទេ? ណូអេនិយាយ "វានឹងមានភ្លៀង មានភ្លៀង ហើយផែនដីនឹងត្រូវបំផ្លាញអស់ទៅ។" វាក៏ភ្លៀង។ នោះវាមិនត្រូវការ ការបកស្រាយអ្វីឡើយ។ វាមានភ្លៀងដោយព្រោះព្រះជាម្ចាស់នៅក្នុងណូអេដែលមានបន្ទូល "វានឹងមានភ្លៀង។" គាត់គឺជាព្យាការី ហើយភស្តុតាងទាំងនេះ ជាអ្វីដែលគាត់បាននិយាយនោះក៏មានមែន។ ដូច្នេះគេមិនចាំបាច់បកស្រាយឡើយ។

22 មានអ្នកខ្លះនៅជុំវិញនោះអាចនិយាយថា "មនុស្សនេះមិនដឹងថាខ្លួនគាត់កំពុងនិយាយពីអ្វីឡើយ" ។

23 ប៉ុន្តែព្រះជាម្ចាស់តែងតែសន្យា "បើមាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា ជាមនុស្សខាងវិញ្ញាណ ឬ ជាហោរ៉ា ហើយអ្វីដែលគាត់និយាយកើតមានពិត ដូច្នេះ ចូរស្ដាប់ចុះ។" ត្រូវហើយ ព្រោះវាជាការពិត។ វាត្រូវតែស្របតាមព្រះបន្ទូល។ ហើយ ណូអេក៏ស្របតាមព្រះបន្ទូលដែរ។ ដូច្នេះគាត់ក៏ថ្លែងទំនាយថានឹងមានភ្លៀង ហើយ វាក៏ភ្លៀង។ ដូច្នេះមិនត្រូវការបកស្រាយអ្វីសម្រាប់ការនោះឡើយ ព្រោះវាបែបនោះ ឯង។

24 អេសាយបាននិយាយថា "ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះ" ហើយនាងក៏ មាន។ ឥឡូវនេះជារឿងគួរខ្លាចមិនធម្មតា។ ត្បិតឃើញទេ វាមានរយៈពេលរាប់រយ ឆ្នាំក្រោយទៀតមុន ស្ត្រីព្រហ្មចារីមានផ្ទៃពោះ។

25 វាមិនមែនជារឿងធម្មតារហូតដល់បុរសចិត្តល្អម្នាក់ឈ្មោះយ៉ូសែប ប្ដីរបស់ នាង "ជាមនុស្សសុចរិត និង មិនបានធ្វើឱ្យរឿងនាងទៅជាសាធារណៈ..." ជា មនុស្សល្អនៅសម័យនោះ វាត្រូវជាយ៉ាងណាដែរ ចំពោះយ៉ូសែបពេលដែលគាត់ ភ្ជាប់ពាក្យ ត្រូវរៀបការជាមួយម៉ារី។

26 នាងជាប់ចំណងប្ដីប្រពន្ធ។ នៅសម័យនោះបើកាត់ផ្ដាច់ គឺប្រៀបបាននឹងការ ធ្វើកំផិត។ ហើយជាការពិត សម្រាប់យ៉ូសែប វាហាក់បីដូចជាម៉ារីព្យាយាមប្រើ គាត់ដើម្បីបិទបាំង ឬយកគាត់ជាខែលចំពោះអ្វីដែលធ្វើខុស ព្រោះនៅត្រង់នេះ នាងត្រូវបានឃើញថានឹងក្លាយជាម្ដាយរបស់គេ ដែលមិនបានរៀបការ គឺត្រឹមតែ ភ្ជាប់ពាក្យ។ អន្ទាក់ល្បិច នៅត្រង់ចំណុចនោះ អាចត្រូវគេគប់សម្លាប់នឹងថ្ម វា ត្រូវបែបនេះ បើធ្វើតាមច្បាប់។

27 ហើយ យ៉ូសែបដែលជាប្ដី ជាមនុស្សសុចរិត ជាមនុស្សសុចរិតណាស់។ គាត់ ជឿដល់ព្រះជាម្ចាស់។ ហើយពេលនាងស្វែងរកគាត់សម្រាប់សេចក្ដីស្រឡាញ់ ទាំង នោះ ដោយភ្នែកស្រទន់ធំៗ ហើយនិយាយ "យ៉ូសែប ទេវតាកាព្រីយ៉ែល បាន មក ជួបនឹងខ្ញុំ ហើយប្រាប់ខ្ញុំថា ខ្ញុំនឹងមានគភ៌ ដោយមិនបានស្គាល់ប្រុសណា សោះ។"

28 ឥឡូវ បើយ៉ូសែបគ្រាន់តែសម្លឹងមើលខគម្ពីរ ព្យាការី បានទាយថានាងនឹង កើតមានដូច្នេះ! វាគឺជាព្រះជាម្ចាស់ផ្ទាល់ដែលបកស្រាយព្រះបន្ទូលនោះ! ឃើញ ទេ? ប៉ុន្តែវា មិនធម្មតាឡើយ។

29 នោះជាបញ្ហានៅសម័យកាលនោះ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្លាយជាចម្លែកសម្រាប់មនុស្សទាំងនោះ វាចម្លែកពេក។ ព្រះជាម្ចាស់តែងធ្វើអ្វីដែលមិនធម្មតា។ ព្រះនៅទីណា មានរឿងមិនធម្មតានៅទីនោះ។ វាជារឿងដែលផ្ទុយពីរបៀបលោកិយ៍ ព្រោះពួកគេចង់ឱ្យអ្វីៗស្របទៅតាមការគិតរបស់គេដែលគួរតែកើត។ ប៉ុន្តែព្រះជាម្ចាស់យាងចូលមក ហើយធ្វើការដែលមិនធម្មតា។

30 "តើស្ត្រីព្រហ្មចារី អាចមានផ្ទៃពោះដោយរបៀបណា?" គាត់ស្មោះត្រង់ណាស់ គាត់បានស្វែងរកព្រះជាម្ចាស់ចំពោះរឿងនោះ។

31 ហើយ ក្រោយមកព្រះជាម្ចាស់មានបន្ទូលទៅកាន់គាត់តាមរយៈយល់សប្តិ ហើយ មានបន្ទូលថា "យ៉ូសែប ជាកូនរបស់ដាវីឌ កុំឱ្យខ្លាចនឹងយកម៉ារីធ្វើជាប្រពន្ធអ្នកឡើយ ព្រោះកូនដែលនាងមានគឺជាព្រះវិញ្ញាណបរិសុទ្ធ។ ព្រះជាម្ចាស់បានគ្របបាំងនាង។ នេះជាអ្វីដែលបានកើតមាន។"

32 តើអ្នកធ្លាប់បានកត់សម្គាល់ពីរបៀបដែលព្រះទំនាក់ទំនងទៅកាន់យ៉ូសែប នៅទីនោះទេ? នៅរបៀបបន្ទាប់ តាមការយល់សប្តិ។ ឥឡូវ យើងដឹងថាមានការយល់សប្តិ យើងជឿលើការយល់សប្តិ។ ខ្ញុំជឿលើការយល់សប្តិ។ ជារៀងមក... ព្រះជាម្ចាស់តែងមានទំនាក់ទំនងជាមួយមនុស្សក្នុងសុបិន្ត។ ប៉ុន្តែការយល់សប្តិជារឿងបន្ទាប់បន្សំប៉ុណ្ណោះ ឃើញទេ វាអាចខុសឬត្រូវទាល់តែមានការបកស្រាយ។ ប៉ុន្តែគាត់មិនចាំបាច់ការបកស្រាយទេ។គឺព្រះជាម្ចាស់ផ្ទាល់ជាអ្នកមានបន្ទូលទៅកាន់យ៉ូសែប ដោយព្រោះពេលនោះមិនមានព្យាការីសម្រាប់ទឹកដីគេនៅសម័យនោះដើម្បីបកស្រាយឡើយ។ គឺមិនមានព្យាការីណាមួយឡើយក្នុងរយៈពេល៤០០ឆ្នាំ។ ដូច្នេះអ្វីដែលល្អបំផុតគឺព្រះជាម្ចាស់យកព្រះទ័យទុកដាក់នឹងការសង្គ្រោះធ្វើឡើងតាមរយៈព្រះបុត្រារបស់ទ្រង់ ក៏បានមានបន្ទូលទៅកាន់យ៉ូសែបតាមរយៈការយល់សប្តិ និងមិនចាំបាច់មានការបកស្រាយទេ។ ព្រះអង្គមានបន្ទូល "ស្ត្រីនោះសុចរិតទេ។ គឺបុត្រាបរិសុទ្ធដែលមាននៅក្នុងផ្ទៃនាងគឺជាបុត្រារបស់ព្រះជាម្ចាស់។" វាមិនត្រូវការ ការបកស្រាយឡើយ។

33 ព្រះជាម្ចាស់បកស្រាយដោយព្រះអង្គផ្ទាល់ចំពោះអ្នកស្មោះត្រង់ ចិត្តស្មោះត្រង់ មនុស្សប្រុសស្រីដែលសម្លឹងមើល—អ្វីជាអាថ៌កំបាំង បើអ្នកស្មោះត្រង់ និងគោរពកោតខ្លាច និងជឿបាន ព្រះជាម្ចាស់មានរបៀបដែលបកស្រាយសម្រាប់អ្នក។ ទីមួយ ត្រូវរកឲ្យឃើញ ប្រសិនបើវាជាការសន្យា។ ប្រសិនបើយ៉ូសែប

បានដកថយចេញពីទំនៀមទម្លាប់ហើយត្រឡប់មកព្រះគម្ពីរ ហើយស្វែករកក្នុង អេសាយចែងថានាងនឹងមានគភ៌ពិត។

34 ហើយអ្វីដែលបាននិយាយ និង កំណើតរបស់ទ្រង់ ហើយអ្វីទាំងអស់ត្រូវបាន និយាយតាមបទគម្ពីរ "ដោយហោរ៉ាបរិសុទ្ធ" ដូចពេត្រុសបាននិយាយ។ ហើយ គ្មានមនុស្សណាមានសិទ្ធិ យកការបកស្រាយផ្ទាល់ខ្លួនចំពោះរឿងនោះឡើយ។ វាកើតមានដូចអ្វីដែលព្រះជាម្ចាស់មានបន្ទូល។ ព្រះអង្គជាការបើកឱ្យឃើញពី ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបានសន្យាសម្រាប់សម័យនោះ។ ព្រះជាម្ចាស់ មានបន្ទូល ដូច្នេះវាក៏កើតមាន។ នោះជាការស្រេច។

35 ព្រះយេស៊ូមានបន្ទូល...ពេលទ្រង់គង់លើផែនដី ពេលពួកគេមិនអាចយល់ ពន្ធកិច្ចទ្រង់ វាអស្ចារ្យណាស់ វាមានព្រឹត្តិការណ៍សម្បើមពេក (ពួកគេមិនអាច យល់បាន) មានភាពជាព្រឹត្តិការណ៍អស្ចារ្យ។ ពួកគេមិនអាចយល់ពីទ្រង់បាន។ ព្រះអង្គមានបន្ទូល "ចូរស្វែងរកក្នុងបទគម្ពីរ!" (ខ្ញុំសង្ឃឹមថា ខ្ញុំមិនបានបិទអ្នក នៅត្រង់នេះទេ ចូរឲ្យផុសផុលចំពោះការនោះ។) "រកមើលក្នុងបទគម្ពីរ ព្រោះក្នុង បទគម្ពីរអ្នកគិតថាអ្នកអាចរកបានជីវិតអស់កល្ប ហើយពួកវាគ្រាន់តែធ្វើបន្ទាល់ពី ខ្ញុំប៉ុណ្ណោះ។" ឃើញទេ? "ពួកវាគ្រាន់តែជារឿងមួយដែលប្រាប់ថាខ្ញុំជានរណា។"

36 ឃើញទេ ព្រះជាម្ចាស់ដាក់ព្រះបន្ទូល។ នៅសម័យនោះជាការបើកសម្តែង របស់ព្រះជាម្ចាស់ ព្រះជាម្ចាស់(អេម៉ាញូអែល)ដែលគង់ជាមួយយើង "ព្រះនាម ទ្រង់ត្រូវបានហៅថាជាការអស្ចារ្យ ជាអ្នកផ្តល់យោបល់ ជាអម្ចាស់នៃសេចក្តី សុខសាន្ត ជាព្រះមានចេស្តា ជាព្រះបិតាគង់នៅអស់កល្ប។ ហើយព្រះនាមទ្រង់ គួរត្រូវបានហៅថា *អេម៉ាញូអែល* 'ព្រះអង្គគង់ជាមួយយើង'"។ ព្រះជាម្ចាស់គង់ក្នុង ដាវីឌ។ ព្រះអង្គគង់ក្នុងម៉ូសេ។ ព្រះជាម្ចាស់! ជាព្រះដែលតរៀងមក បើកសម្តែង ឱ្យឃើញអង្គទ្រង់នៅសម័យនោះ។ ប៉ុន្តែនៅសម័យនេះ "ស្រីក្រមុំព្រហ្មចារីនឹង មានគភ៌ ហើយនាងនឹងបង្កើតបានបុត្រាមួយអង្គ ហើយព្រះអង្គនឹងគង់ជាមួយ យើង។"

37 នោះជាអ្វីដែលពួកគេបានឆ្កាងទ្រង់ ដែលតាំងអង្គទ្រង់ជាព្រះ ហើយក៏ បំបែក ថ្ងៃសប្ប័ទ។ ព្រះអង្គជា—ព្រះអង្គជាព្រះលើថ្ងៃសប្ប័ទ ហើយព្រះអង្គជា ព្រះ។ ហើយទ្រង់មិនមែនជាមនុស្សធម្មតាឡើយ ឬ ជាព្យាការីធម្មតាទេ (ទោះ បើព្រះអង្គជាមនុស្សធម្មតា និងជាព្យាការីក៏ដោយ) ប៉ុន្តែព្រះអង្គជាព្យាការីមាន

ភាពជាព្រះ។ ហើយព្រះអង្គគឺជាសេចក្ដីបំពេញនៃព្រះបន្ទូល គឺតាមសេចក្ដីពិត ដែលព្រះជាម្ចាស់មានបន្ទូល ព្រះអង្គនឹងធ្វើ។ មានបន្ទូលថា "នរណាម្នាក់នៃអ្នករាល់គ្នា អាចកាត់ទោសខ្ញុំចំពោះបាប? ចូរស្វែងរកនៅក្នុងបទគម្ពីរ! ក្នុងគម្ពីរ អ្នកគិតថាអ្នករាល់គ្នាអាចរកបានជីវិតអស់កល្ប ហើយបទគម្ពីរនោះជាទីបន្ទាល់ពីខ្ញុំ។" ប៉ុន្តែតាមទំនៀមទម្លាប់នោះ គឺពួកគេរស់នៅជាពន្លឺនៃសម័យមួយទៀត។

38 ដូចដែលខ្ញុំបានអធិប្បាយ កាលពីប៉ុន្មានសប្ដាហ៍មុន *"រស់នៅក្នុងពន្លឺមួយ។"* ពន្លឺ "ការចាំង" ព្រះអាទិត្យចាំងពន្លឺ ហើយវាខុស។ ហើយពន្លឺនៃសម័យកាលមួយទៀតគឺជាការឆ្លុះបញ្ចាំងដែលខុស។ មនុស្សតែងតែដើរក្នុងអ្វីដែលកើតឡើងជាយូរឆ្នាំកន្លងទៅ។ លូធើរៀន បានដើរក្នុងពន្លឺនៃលូធើរៀន។ ពន្លឺថ្ងៃរបស់លូធើរៀនល្អក្នុងសម័យកាលរបស់ខ្លួន វេស្លេល្អក្នុងសម័យរបស់គាត់ ពេនទីកុស្តល្អក្នុងសម័យរបស់គេ។ យើងត្រូវឡើងជណ្ដើរ យើងរស់នៅសម័យកាលមួយទៀត! យើងកំពុងបន្ត បន្ត យើងមិនអាចនៅតែសម្លឹងងាកក្រោយឡើយ។

39 ពេលយើងដាក់ខ្លួនចុះក្នុងអ្វីមួយ យើងគិតថាយើងមានវាជាសេចក្ដីធ្វើឡើងគ្រប់ការ យើងបានបង្កើតវប្បធម៌ខ្លួនឯងមួយឡើង ហើយវាជាការត្រឹមត្រូវសម្រាប់ថ្ងៃនោះ ប៉ុន្តែយើងត្រូវបន្តទៅមុខ! ពិនិត្យមើលខគម្ពីរ ហើយមើលអ្វីដែលបានសន្យានៅថ្ងៃនេះ ដូច្នេះយើងដឹងថាយើងនៅត្រង់ណា។ ដូច្នេះយើងអាចប្រាប់កន្លែងដែលយើងឈរ។

40 លូធើ អ្នកអាចមើលក្នុងគម្ពីរហើយឃើញក្នុងនោះ—នៅសម័យសាឌីស អ្នកអាចមើលឃើញដូចគ្នាដែលជាអ្វីបានសន្យា។ សម្លឹងមើលអ្វីដែលអ្នកដើរតាម គេធ្វើរឿងមក មើលអ្វីដែលអាចជួបជាមួយគាត់បាន ជាការដាក់ស្ដែង "ភាពល្បិចឆ្លាតវៃនៃមនុស្ស" ធ្វើកំណែទម្រង់។ ពិនិត្យមើល វេស្លី និង អ្វីទៀត។ វាតមករហូតដល់សម័យពេនទីកុស្ត ហើយតមកសម័យនោះ មើលពីរបៀបវាធ្វើដំណើរ។ ពិនិត្យមើលបទគម្ពីរហើយឃើញថាយើងនៅត្រង់ណា។ នោះជាហេតុផលដែលព្រះយេស៊ូមានបន្ទូល "ស្រាវជ្រាវមើលបទគម្ពីរ!"

41 មើលថាយើងកំពុងនៅឯណា! ខ្ញុំជឿថាយើងកំពុងនៅក្នុងពេលនៃការយាងមករបស់បុត្រានៃព្រះជាម្ចាស់។ ខ្ញុំជឿថាយើងកំពុងតែនៅសម័យ—វេលាដែលព្រះអង្គអាចលេចចេញមកគ្រប់ពេល។ ខ្ញុំជឿថាព្រះបន្ទូលប្រកាសបែបនោះ ថាយើងកំពុងតែនៅវេលាចុងក្រោយនៃពិភពលោកនេះ។ ខ្ញុំអាចឃើញអ្វីមួយដែល

កំពុងតែមានរូបរាងឡើង។ ឃើញទេ អំពីអ្វីដែលក្រុមប្រឹក្សានៃគ្រីស្ទានទាំងមូលដឹកនាំក្រុមជំនុំទៅរកសេចក្ដីនោះគឺទៅរកទីសម្គាល់នៃសត្វចតុបាត។ និងឃើញចក្រភពរ៉ូម និងអ្វីដែលវាកំពុងតែធ្វើ និងអ្វីផ្សេងទៀតរបស់វាដែរ។ ឃើញពួកវាមកជាមួយគ្នា ហើយពន្លត់ពន្លឺ និងបិទដំណឹងល្អ។ គ្រប់គ្នានឹងក្លាយជាកម្មសិទ្ធិរបស់វាហើយ និងដើរក្នុងពន្លឺរបស់វា បើមិនដូច្នេះអ្នកមិនអាចដើរបានឡើយ។ ឃើញទេ យើងកំពុងនៅពេលចុងក្រោយ។ គ្មានអ្វីនៅសេសសល់សម្រាប់យើងទៀតឡើយ ប៉ុន្តែមានតែការតោងជាប់ជាមួយព្រះជាម្ចាស់ និងជឿព្រះបន្ទូលទ្រង់តែប៉ុណ្ណោះ។ ព្រះបន្ទូលតែងតែត្រឹមត្រូវជានិច្ច។

42 នៅសម័យកាលក្រុមជំនុំឡៅឌីសេ ជាម័យកាលក្រុមជំនុំតែមួយក្នុងចំណោមក្រុមជំនុំទាំងអស់ ដែលព្រះគ្រិស្តត្រូវបានដាក់នៅខាងក្រៅក្រុមជំនុំ។ ព្រះអង្គនៅខាងក្រៅហើយ កំពុងតែគោះ។ មានអ្វីកើតឡើង? ក្រុមប្រឹក្សាគ្រិស្តបរិស័ទ ជាអ្វីដែលបានរុញព្រះអង្គទៅក្រៅ។ ព្រះគម្ពីរបានប្រាប់ថា ព្រះអង្គត្រូវបានគេដាក់នៅខាងក្រៅ ហើយព្រះអង្គក៏បានត្រូវបានដាក់មែន។ វាបានបិទអ្វី? ព្រះបន្ទូល។ ហើយព្រះអង្គជាព្រះបន្ទូល ព្រះអង្គគឺនៅតែជាព្រះបន្ទូលជានិច្ច ហើយព្រះអង្គនៅតែជាព្រះបន្ទូលនៅយប់នេះដដែល! ព្រះអង្គជាព្រះបន្ទូល។

43 ព្រះគម្ពីរបាននិយាយ "ព្រះបន្ទូលមុតជាង និងមានអំណាចជាងដាវមុខពីរ។" គម្ពីរហេព្រើជំពូកទី៤"ពិចារណាអស់ទាំងគំនិតដែលចិត្តគិតហើយដែលសំរេចដែរ។" នោះគឺជាព្រះបន្ទូល! ពួកគេគួរតែស្គាល់ថាទ្រង់ជាអ្នកណា ពេលព្រះយេស៊ូមានបន្ទូលបែបនោះនៅសម័យនោះ។

44 ពិនិត្យមើលអ្វីដែលព្រះអង្គបានធ្វើ។ ថ្ងៃមួយព្រះអង្គឈរនៅទីនោះ នៅដើមដំបូងដៃព័ន្ធកិច្ចរបស់ព្រះអង្គ។ មានមនុស្សមកជួបទ្រង់ឈ្មោះថាស៊ីម៉ូន ស៊ីម៉ូនពេត្រុស។ ហើយពេលពេត្រុសមើលមកទ្រង់ ហើយ—ហើយឃើញទ្រង់ ព្រះយេស៊ូមានបន្ទូលទៅគាត់ថា "អ្នកឈ្មោះថាស៊ីម៉ូន ជាកូនរបស់យ៉ូណាស។" (គាត់អាចដឹងពីអ្វីដែលម៉ូសេបាននិយាយ "ព្រះអម្ចាស់ជាព្រះនៃអ្នកនឹងលើកឱ្យមានហោរ៉ាម្នាក់ដូចជាខ្ញុំ ហើយអ្នកត្រូវតែស្ដាប់គាត់")។ ហើយទីនេះមានមនុស្សម្នាក់ដែលជាអ្នកមិនធ្លាប់ជួបគាត់ពីមុនសោះក្នុងជីវិត បាននិយាយមកគាត់ "អ្នកឈ្មោះស៊ីម៉ូន និង អ្នកជាកូនរបស់យ៉ូណាស។" ហេតុអ្វី គាត់ដឹងបានច្បាស់ដូច្នេះពីព្រោះមិន

មាន...ពួកគេមិនមានព្យាការីរាប់រយឆ្នាំមកហើយឥឡូវមានមនុស្សម្នាក់ប្រាប់គាត់ថាគាត់ជានរណា។ គ្មានចម្ងល់អ្វីទេ គាត់គួរទទួលយកវា!

45 ភីលីពពេលនោះ បានចេញទៅហើយ—ហើយរកឃើញណាថាណែលក្រោមដើមឈើ ហើយនាំគាត់ទៅកាន់ព្រះយេស៊ូ។ ព្រះយេស៊ូមានបន្ទូល "មើលជនជាតិអ៊ីស្រាអែលដែលគ្មានទោសសោះ។"

គាត់និយាយ "លោកគ្រូអើយ តើលោកស្គាល់ខ្ញុំពីពេលណាមក?"

46 ទ្រង់មានបន្ទូល "មុនភីលីព ហៅអ្នកពេលអ្នកនៅក្រោមដើមឈើខ្ញុំបានឃើញអ្នកហើយ។"

47 គាត់និយាយ "លោកគ្រូអើយ លោកជាព្រះបុត្រារបស់ព្រះ! ព្រះអង្គជាស្តេចរបស់អ៊ីស្រាអែល។" គាត់ដឹងបែបនោះ!ជាអ្វីទៅ?វាមិនត្រូវការការបកស្រាយឡើយ ព្រះយេហូវ៉ាមានបន្ទូលបែបនោះ!

48 មានអ្នកដែលឈរនៅទីនោះគេមិនជឿឡើយ។ គេនិយាយថា"មនុស្សម្នាក់នេះជាបៀសេប៊ូប។ គាត់មាន—គាត់ចេះល្បិចបំភាន់ដែលចេញមក។ គាត់—គាត់ជាគ្រូទាយឬជាអ្វីមួយ។"

49 ព្រះយេស៊ូសម្លឹងមើលពួកគេហើយមានបន្ទូល "បើអ្នកនិយាយបែបនោះទៅកាន់ព្រះបុត្រានោះអាចលើកលែងទោសឱ្យបាន។ ប៉ុន្តែពេលព្រះវិញ្ញាណបរិសុទ្ធយាងមកហើយធ្វើការដូចគ្នា ហើយអ្នកនិយាយទាស់នឹងទ្រង់ នោះគ្មានការអត់ទោសដល់អ្នកឡើយ ទោះក្នុងលោកនេះ ឬលោកខាងក្រោយដែលមកទៀត។" ព្រះអង្គកំពុងតែថ្លែងទំនាយពីសម័យរបស់យើង ជាសម័យដែលយើងអាចមើលឃើញ។ ព្រោះព្រះអង្គនៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និង រៀងរហូតទៅ។

ចងចាំ នោះគឺជាព្រះគ្រិស្តដែលនៅក្នុងម៉ូសេ។

50 នោះគឺជាព្រះយេស៊ូ ដែលនៅក្នុងដាវីឌ។ ពេលដែលដាវីឌជាកូន...ដាវីឌបានឡើងទៅលើភ្នំ ជាស្តេចដែលគេបដិសេធ ហើយយំពីរឿងក្រុងយេរូសាឡឹម វាគ្មានអ្វីក្រៅពីព្រះយេស៊ូដែលនៅក្នុងខ្លួនគាត់។ ប្រហែលប្រាំបីរយឆ្នាំក្រោយមក បុត្ររបស់ដាវីឌឡើងទៅលើភ្នំអូលីវ ហើយមើលមកក្រុងយេរូសាឡឹមក៏យំដែរ ហើយនិយាយថា "យេរូសាឡឹម យេរូសាឡឹម តើប៉ុន្មានដងហើយដែលខ្ញុំត្រូវគ្របបាំងអ្នកដូចជាមេមាន់បណ្តើរកូន ប៉ុន្តែអ្នកមិនដឹងឡើយ!"

51 ពេលយ៉ូសែបនៅក្នុងគុក នោះក៏ជាព្រះយេស៊ូដែរ។ ពេលគាត់ត្រូវបានគេលក់តម្លៃជិតសាមសិបស្លឹង នោះគឺជាព្រះយេស៊ូហើយ។ ពេលគាត់ត្រូវបានតែងតាំងជាមនុស្សរបស់ប៉ូទីផា នោះគឺជាព្រះយេស៊ូហើយ។ ពេលគាត់តាំងនៅខាងស្ដាំស្ដេចផារ៉ោន។ ហើយពេលគាត់ចេញទៅ គ្រប់គ្នា...សម្លេងត្រែ គ្រប់គ្នាត្រូវតែលុតជង្គង់ នោះគឺជាព្រះយេស៊ូហើយ។ គ្មាននរណាអាចទៅជិតស្ដេចផារ៉ោនលើកលែងតែតាម—តាមរយៈយ៉ូសែប គ្មាននរណាអាចមកព្រះជាម្ចាស់ លើកលែងតែតាមរយៈព្រះយេស៊ូ។ វាគឺជាព្រះយេស៊ូ ព្រះបន្ទូលថ្លែងទំនាយ ត្រូវបានបំពេញ ថ្លែងជាស្រមោល និងតាមប្រភេទណាមួយ។

52 ពេលព្រះយេស៊ូនៅទីនេះលើផែនដី ទ្រង់បានធ្វើដូចគ្នានិងអ្វីដែលហោរ៉ាបានធ្វើដែរ ដូច្នេះហើយបានជាគេដឹងថាព្រះអង្គជាការបើកសម្ដែងនៃព្រះបន្ទូលព្រះជាម្ចាស់។ វាមិនត្រូវការអ្នកបកស្រាយឡើយ។

53 ពេលដែលណាថាណែលឃើញបែបនេះ គាត់មានក្រាបចុះ និយាយ "លោកជាស្ដេចនៃអ៊ីស្រាអែល ព្រះបុត្រារបស់ព្រះ ជាស្ដេចនៃអ៊ីស្រាអែល។ យើងស្គាល់ទ្រង់ គ្មាននរណាអាចធ្វើការនេះឡើយ។"

54 លោកនីកូដេម មកជួបពេលយប់ និយាយដូចគ្នាចំពោះពួកផារ៉ាស៊ី។ ប៉ុន្តែអ្នកឃើញទេ ពួកគេត្រូវថ្កក់ជាប់នៅក្នុងក្រុមប្រឹក្សាជំនឿរបស់គេដែលថាពួកគេមិនអាចទទួលបាន។ គាត់បង្ហាញអ្វីដែលគេនិយាយ និយាយថា "លោកគ្រូ យើង..." នរណាគេ "យើង"? ក្រុមប្រឹក្សារបស់គេ! "យើងដឹងថាលោកជាគ្រូដែលមកពីព្រះជាម្ចាស់ ព្រោះគ្មានមនុស្សណាអាចធ្វើការទាំងនេះ លើកលែងតែព្រះជាម្ចាស់នៅក្នុងអ្នកនោះ។" ពួកគេស្គាល់ ពួកគេដឹងដូច្នេះ ប៉ុន្តែពួកគេថ្កក់ជាប់នៅត្រង់នោះ។

55 ហើយព្រះជាម្ចាស់ នៅកាលពីសែសិបឆ្នាំកន្លងមក បានអង្រួនប្រជាជាតិដោយការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ ហើយមនុស្សប្រុសស្រីនៅក្រៅពីនោះព្រោះពួកគេនៅថ្កក់ជាប់នឹងរឿងដូចគ្នា រស់នៅក្នុងពន្លឺមួយនៃសម័យផ្សេង។ មានបញ្ហាអ្វី? គ្រប់គ្នាចង់ក្លាយជាមេតូឌីស្ដ បាបទីស្ទ ព្រីសប៊ីធីរៀន លូធីរៀន និងអ្វីផ្សេងទៀត។ ឃើញទេ វាជាពន្លឺ។

56 ពួកគេរស់នៅក្នុងសម័យកាលរបស់ម៉ូសេ។ តើគាត់និយាយយ៉ាងណា? គាត់និយាយ...ពួកគេនិយាយ "យើងជាសិស្សរបស់ម៉ូសេ។"

57 ព្រះអង្គមានបន្ទូល "បើអ្នកស្គាល់ម៉ូសេ អ្នកក៏ស្គាល់ខ្ញុំដែរ ម៉ូសេបានសរសេរ
សេចក្ដីនេះអំពីខ្ញុំ!"

58 បើអ្នកស្គាល់លូធឺ អ្នកនឹងស្គាល់សម័យនេះ! បើអ្នកស្គាល់មេតូឌីស្ត អ្នកនឹង
ស្គាល់សម័យនេះ! ព្រោះព្រះគ្រិស្តបានសរសេរពីសម័យនេះ! ព្រះបន្ទូលដែលត្រូវ
បំពេញ ត្រូវតែបំពេញនៅក្នុងសម័យនេះ។ វាមិនត្រូវការនរណាម្នាក់បកស្រាយ
ឡើយ ព្រះជាម្ចាស់បានធ្វើការបកស្រាយដោយព្រះអង្គផ្ទាល់។ ព្រះជាម្ចាស់
បកស្រាយពីព្រះអង្គផ្ទាល់ ព្រោះព្រះអង្គជាអង្គតែមួយដែលអាចបកស្រាយបាន។
សេចក្ដីសន្យារបស់ព្រះជាម្ចាស់តែងតែកាត់សេចក្ដីថាត្រឹមត្រូវពីអ្វីដែលព្រះអង្គ
មានបន្ទូល ហើយនោះជាការបកស្រាយផ្ទាល់។

59 ឥឡូវ ព្រះយេស៊ូ (ដើម្បីសន្សំពេលវេលា) ព្រះយេស៊ូមានបន្ទូល ក្នុងគម្ពីរ
យ៉ូហាន ជំពូកទី១៤ ខ១២ "អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើ
ដែរ។" តើព្រះអង្គមានបន្ទូលបែបនេះ? ជាការពិត។ មិនត្រូវការការបកស្រាយណា
ផ្សេងឡើយ។ នៅពេលនរណាម្នាក់ធ្វើការនោះ នោះគឺជាព្រះជាម្ចាស់។ ជាការពិត!

60 ព្រះអង្គមានបន្ទូលបែបនោះ "ដូចជាសម័យកាលឡុតយ៉ាងណា ថ្ងៃដែលបុត្រ
របស់មនុស្សមកវិញក៏យ៉ាងនោះដែរ។" ព្រះយេស៊ូមានបន្ទូលបែបនោះ។ តើទ្រង់
មានបន្ទូលបែបនេះទេ? ជាការពិត ព្រះអង្គមានបន្ទូលមែន! នោះមិនត្រូវការការ
បកស្រាយឡើយ។

ពួកគេនិយាយ "ល្អនោះមានន័យថា..."

61 វាមានន័យដូចអ្វីដែលព្រះអង្គមានបន្ទូល! "ដូចជាសម័យកាលឡុត
យ៉ាងណា ថ្ងៃដែលបុត្ររបស់មនុស្សមកវិញក៏យ៉ាងនោះដែរ។" តើសម័យរបស់
ឡុតគឺយ៉ាងណា? ចូរត្រឡប់ទៅមើលបន្តិច ស្វែងរកអ្វីដែលគេបានធ្វើ។

62 មានមនុស្សបីថ្នាក់នៅសម័យឡុត: អ្នកជឿ អ្នកធ្វើជាជឿ និង អ្នកមិនជឿ។
មាននៅក្នុងគ្រប់ក្រុមមនុស្ស ដូចគ្នា។

យើងឃើញថាអ្នកស្រុកសូដុំជាមនុស្សមិនជឿ

ឡុតជា អ្នកធ្វើជាជឿ

63 អ័ប្រាហាំ ជាអ្នកជឿ។ គាត់ជាម្នាក់ដែលបានបញ្ជាក់ពីការតាំងសញ្ញា។ គាត់
ជាម្នាក់ដែលទន្ទឹងចាំ បុត្រនៃសេចក្ដីសន្យា។ គាត់ជាមនុស្សម្នាក់ដែលរំពឹងគិត

ពីសេចក្ដីនោះ។ អាម៉ែន។ (ខ្ញុំមិនមែន "ធ្វើអាម៉ែន" ចេះតែនិយាយនោះទេ។ *អាម៉ែន* មានន័យថា "ចូរឱ្យវាបានដូច្នោះ!") ហើយនោះជាការត្រឹមត្រូវ។ អ័ប្រាហាំមិននៅក្នុងក្រុងសូដុំទេ។ គាត់ជាប្រភេទតំណាងឲ្យក្រុមជំនុំនាបច្ចុប្បន្ន។

64 ឡុតប្រៀបដូចជា ប្រភេទក្រុមជំនុំនិកាយក្នុងក្រុងសូដុំ។ ពិនិត្យមើលព្រះគម្ពីរនិយាយដូច្នោះ "បាបរបស់ក្រុងសូដុំ បានរុកគួនដល់ព្រលឹងសេចក្ដីសុចរិតរបស់គាត់រាល់ថ្ងៃ។" ហេតុអ្វីបានជាគាត់មិនមានជំហរឈរឡើងទាស់នឹងវា? ព្រោះមានមនុស្សល្អជាច្រើនអង្គុយនៅក្នុងព្រះវិហារសព្វថ្ងៃ សម្លឹងមើល គេមើលស្ត្រីដែលស្លៀកខ្លី និងមនុស្សដែលកំពុងធ្វើការនេះ ហើយសមាជិកពួកគេចេញទៅ លេងវាយកូនហ្គោលនៅថ្ងៃអាទិត្យ និងពិធីជប់លៀងកំសាន្ត និងហែលទឹក ឬ អ្វីទៀតជំនួសឱ្យការទៅព្រះវិហារ។ អង្គុយនៅផ្ទះនៅយប់ថ្ងៃពុធ មើលទូរទស្សន៍ ជំនួសការទៅចូលរួមព្រះវិហារ។ ពួកគេមានអារម្មណ៍ថាចង់និយាយអ្វីពីវា ប៉ុន្តែគណៈកម្មការនឹងដេញគេចេញ។ អ្វីជាបញ្ហា? វាគឺជាឡុតម្ដងទៀត អើតតាមបង្អួចនិងសម្លឹងមើលបាប ហើយភ័យខ្លាចក្នុងការហៅថាជា "បាប"!

65 អ័ប្រាហាំមិននៅក្នុងភាពកកខ្វក់នោះទេ គាត់នៅខាងក្រៅ។ គាត់ជាប្រភេទនៃក្រុមជំនុំខាងវិញ្ញាណ។ ឥឡូវមើលអ្វីដែលកើតឡើង ដូចនៅពេលចុងក្រោយមុនពេលដែលភ្លើងធ្លាក់មក។ ហើយពួកគេជាសាសន៍ដទៃ។ វាជាស្រមោលមុនដែលភ្លើងធ្លាក់មកពិភពរបស់សាសន៍ដទៃនាបច្ចុប្បន្ន ពេលដែលនរគទាំងឡាយបានបែកបាក់ហើយពួកគេនឹងត្រូវឆេះ។"ស្ថានសួគ៌នឹងមានភ្លើង" នេះជាព្រះបន្ទូលព្រះអម្ចាស់"ហើយពួកគេនឹងត្រូវឆេះ ដោយកំដៅក្ដៅខ្លាំង។" ដែលវាជាស្រមោល។

66 ឥឡូវចូរធ្វើរូបភាពពួកគេ។ ឥឡូវមានអ័ប្រាហាំចេញមកហើយមិននៅក្នុងក្រុងសូដុំទៀតទេ គាត់នៅខាងក្រៅក្រុងសូដុំ។ ឡុតនៅក្នុងក្រុងនៅឡើយ។

67 មានរឿងចម្លែក នៅព្រឹកក្ដៅមួយ ប្រហែលជាម៉ោង១១ប្រហែលពេលនោះ គាត់ឃើញមនុស្សបីនាក់ចូលមក ជាមនុស្សធម្មតា ដើរតាមផ្លូវ គាត់ឃើញមនុស្សបីនាក់ដើរតាមផ្លូវ។ អ័ប្រាហាំនៅក្រោមដើមសែន សម្រាកកាយ។ គាត់បានចេញមកក្រៅ ប្រហែលមកជាមួយហ្វូងសត្វពេលព្រឹក ឈានចូលក្បែរថ្ងៃត្រង់។ ហើយគាត់ឃើញមនុស្សបីនាក់ចូលមក។ ហើយមានអ្វីមួយពីមនុស្សទាំងនោះ គឺអង្រួនកណ្ដឹង។ អូ ខ្ញុំអើយ!

68 វាតែងតែជាអ្វីអំពីព្រះនៅពេលដែលមកក្នុងចំណោមមនុស្ស កណ្ដឹងរោទ៍ឡើង។ ពួកគេដឹង។ មានអ្វីមួយប្រាប់គេ មានការកាត់សេចក្ដីនៅទីនោះ។

69 អ័ប្រាហាំរត់យ៉ាងលឿន ហើយនិយាយ "ព្រះអម្ចាស់នៃទូលបង្គំអើយ សូមយាងចូលមក ហើយសូមឱ្យទូលបង្គំយកទឹកមក ដើម្បីលាងជើងទ្រង់ ហើយថ្វាយដុំនំប៉័ងនេះ ហើយព្រះអង្គអាចយាងបន្តទៅតាមផ្លូវរបស់ទ្រង់។" ដូច្នេះគាត់ទៅជ្រុងម្ខាង។ គាត់រត់ទៅកាន់ហ្វូងសត្វចិញ្ចឹម ហើយយកកូនគោមកសម្លាប់ហើយប្រាប់ឱ្យអ្នកបម្រើរៀបចំ។ គាត់ចូលទៅក្នុងតង់ជំរុំ នៅពីក្រោយគាត់ ហើយបង្គាប់ឱ្យសារ៉ាច្របាច់ម្សៅ ដើម្បីធ្វើជាអាហារ មួយចំនួន ធ្វើនំប៉័ងខ្លះ និងធ្វើនំដុតលើចង្ក្រាន។ យកអាហារទាំងនោះចេញមក រួចដាក់បម្រើការ។ កាលគាត់កំពុងអង្គុយនៅទីនោះបរិភោគ គេចាប់ផ្ដើមកត់សម្គាល់ មនុស្សនេះសម្លឹងមើលក្រុងសុដុមរហូត។ ហើយទ្រង់មានបន្ទូល...

70 ពីរនាក់ក្នុងចំណោមពួកគេចាំថាត្រូវចុះទៅក្រុងសុដុំ។ ពីរនាក់បានទៅក្រុងសុដុំ។ សូមកុំភ្លេចរឿងនេះ។ ខ្ញុំសំដៅលើអ្វីដែលព្រះយេស៊ូមានបន្ទូល។ ពីរនាក់នៃពួកគេបានទៅក្រុងសុដុំដើម្បីនាំឡុត និងអ្វីៗដែលគាត់រៀបចំរួចរាល់ថានឹងនាំចេញពីទីនោះ។ គឺពួកគេទាំងពីរជាអ្នកចូលទៅ ហើយអធិប្បាយ។ (ហើយមានម្នាក់ដែលនៅពីខាងក្រោយ គឺនៅជាមួយអ័ប្រាហាំ មើលសញ្ញាដែលគាត់ធ្វើ។) ពួកគេ មានសញ្ញាសម្គាល់នៅទីនោះ មាន...ពួកអ្នកក្រុងសូដុំត្រូវបានធ្វើឱ្យងងឹតភ្នែក។ ការអធិប្បាយដំណឹងល្អតែងតែជាភាពងងឹតដល់អ្នកមិនជឿ។ ហើយកំណត់សម្គាល់នោះត្រូវបានធ្វើឡើង។

71 ឥឡូវ មានម្នាក់ឈរនៅពីក្រោយនោះ និងធ្វើទីសម្គាល់ចំពោះមុខអ័ប្រាហាំ។

72 ឥឡូវ តើអ្នកកត់សម្គាល់ពីប្រវត្តិវិទូ តាមរយៈខគម្ពីរ តាមរយៈប្រវត្តិសាស្ត្រ គ្មាននរណាម្នាក់ក្នុងសម័យកាលក្រុមជំនុំដែលក្រុមជំនុំមានឈ្មោះនៅក្នុងពិភពលោក តែនៅក្រៅនិកាយក្រុមជំនុំ ហើយក៏មិនមានមនុស្សណាដែលមានឈ្មោះដូចអ័ប្រាហាំដែរ ហាំ ពីមុខ។ ប៉ុន្តែបច្ចុប្បន្នគេមានប្រ្កា-ហាំ។ ត្រូវទេ។ បន្ត ត្រលប់ទៅនោះពួកគេត្រូវបានហៅតមក។ គាត់ធ្វើតួនាទីមួយយ៉ាងអស្ចារ្យ។ ប្រ្កាហាំ ប៊ីលលីប្រ្កាហាំអ្នកបម្រើព្រះជាម្ចាស់ចេញមកក្នុងចំណោមនិកាយ អ្នក នយោបាយ និងអ្វីផ្សេងទៀត ដែលវិសេស។

73 មានថ្ងៃមួយ ពួកគេចង់ឱ្យគាត់ធ្វើជាប្រធានាធិបតី គាត់បានបដិសេធទាំងស្រុង។ ព្រះជាម្ចាស់បានប្រទានពរគាត់សម្រាប់ការនោះ។ ហេតុអ្វីក្រុមហ៊ុនស្រាវីស្គី គាត់មិនដែលយកមុនគេដូចដែលគួរតែធ្វើនោះទេ។ ពួកគេចំណាយលុយរាប់ពាន់លានដុល្លារ ព្រោះពួកគេបានលក់ចេញ នូវក្រុមហ៊ុនបារី និង អ្វីផ្សេងទៀត។ ឃើញទេ គាត់ចេញពីទីនោះ ជាអ្នកនាំសាររបស់ព្រះជាម្ចាស់ចំពោះក្រុងសូដុំ។ នោះជាការពិត។

74 ប៉ុន្តែសូមចងចាំ មានម្នាក់ដែលនៅជាមួយអ័ប្រាហាំ មនុស្សម្នាក់ផ្សេងទៀតមិនដូចជា ពួកគេទាំងពីរនាក់ទេ ដែលពួកគេចេញទៅ ជាអ្នកផ្សាយដំណឹងល្អសម័យ ទំនើបដើម្បីផ្សាយដំណឹងល្អ។ សូមចងចាំមានម្នាក់ដែលនៅទីនោះ។ ពីរនាក់ចេញទៅតាមផ្លូវ*នោះ* និងម្នាក់នៅ*ទីនេះ*ជាមួយអ័ប្រាហាំ។ ហើយម្នាក់ដែលនៅជាមួយអ័ប្រាហាំផ្តល់សញ្ញាទីសម្គាល់ដល់គាត់។

75 ឥឡូវពិនិត្យមើល ឈ្មោះរបស់គាត់គឺ "អាប់រ៉ាម" ហើយប្រពន្ធរបស់គាត់ឈ្មោះថា "សារ៉ាយ" មុនមួយថ្ងៃឬពីរថ្ងៃនោះ។ ព្រះជាម្ចាស់លេចចេញមកគាត់ ហើយមានបន្ទូលចំពោះគាត់ "យើងនឹងប្តូរឈ្មោះរបស់អ្នកពីអាប់រ៉ាមទៅជា អ័ប្រាហាំ" (មើល ហ្ក្រ-ា-ហាំ មានអក្សរប្រាំមួយ ជាមនុស្សប្រុស។) ប៉ុន្តែ អ័--បុ្រ-ា-ហាំ គឺមានប្រាំពីរ ប្រាំពីរអក្សរ ហាំបញ្ចប់ដោយ ហាំ។

76 ឥឡូវ បន្តមកដល់ទីនេះក្នុងក្រុមជំនុំខាងវិញ្ញាណ មានម្នាក់ដែលនៅជាមួយ អ័ប្រាហាំ ហើយកត់សម្គាល់ពាក្យដែលគាត់និយាយ។ គាត់បាននិយាយ "អ័ប្រាហាំ" (មិនមែន "អាប់រ៉ាម") "អ័ប្រាហាំ ប្រពន្ធអ្នកនៅឯណា" (មិនមែន "ស-ា-រ៉-ា-យ") "ស-ា-រ៉-ា? ប្រពន្ធអ្នកនៅឯណា?"

77 ពិនិត្យមើលអ្វីដែលគាត់និយាយ "នាងនៅក្នុងតង់ពីខាងក្រោយអ្នក។"

78 ហើយទ្រង់មានបន្ទូល "យើងនឹងមកជួបអ្នកម្តងទៀត យើងនឹងមកជួបអ្នក។" ឃើញទេ វាជាពាក្យសព្វនាមឯកវចនៈ ម្នាក់ តាមសេចក្តីសន្យាថាគាត់នឹងធ្វើ។ នោះគឺជាព្រះ! ព្រះអង្គមានបន្ទូល "អញនឹងមកជួបឯង។"

79 ហើយសារ៉ា (ក្នុងរបៀបដែលយើងអាចយល់បាន) សើចផ្ទប់ដៃអាវរបស់នាងសើចខ្លួនឯង គាត់និយាយ "ខ្ញុំ ជាស្ត្រីចាស់អាយុ១០០ឆ្នាំ លោកម្ចាស់" (ដែលជាអ័ប្រាហាំ)"ចាស់ផងដែរឆ្លងកាត់ពេលវេលានៃជីវិតវ័យក្មេងមកហើយ។"និយាយ

ថា"មូលហេតុយើងមិនអាចមានតម្រេកអ្វីយ៉ាងនោះទៀតឡើយខ្ញុំចាស់ហើយ គាត់ ក៏ចាស់ដែរ។" ហើយនិយាយ "យើងមិនអាចមានរឿងបែបនោះឡើយ។" ហើយនិយាយ "ដោយរបៀបណា? រឿងនេះមិនអាចកើតឡើងឡើយ!"

80 ហើយ—បុរស(ព្រះជាម្ចាស់នៅក្នុងភាពជាសាច់ឈាម) និយាយ "ហេតុអ្វីបានជាសារ៉ាសើចនិងសង្ស័យនិយាយពីរឿងនេះ?"នៅក្នុងតង់ពីក្រោយគាត់។

81 ឥឡូវ ចូរពិនិត្យមើល តើនោះមិនមែនដូចជាពន្ធ័កិច្ចដែលព្រះយេស៊ូមានទេឬ! លោកសម្លឹងមើលហ្វូងមនុស្សហើយស្គាល់ពីគំនិតរបស់ពួកគេ។ ព្រះអង្គបានមានបន្ទូលប្រាប់ពេត្រុសពីឈ្មោះរបស់គាត់និង ឈ្មោះឪពុករបស់គាត់។ ក៏បានប្រាប់ណាថាណែល។

82 មានបន្ទូលប្រាប់ស្ត្រីនៅអណ្តូងទឹក ពេលនាងនិយាយ...ព្រះអង្គមានបន្ទូល "សូមឱ្យទឹកខ្ញុំផឹកផង" ឬ "យកទឹកឱ្យខ្ញុំផង។"

83 នាងនិយាយ "លោកម្ចាស់ វាមិនមែនជាប្រពៃណីទេដែលលោកនិយាយ... លោកជាជនជាតិយូដានិយាយជាមួយសាសន៍សាម៉ារី។ យើងមិនមានអ្វីត្រូវទាក់ទងគ្នាឡើយ។"

84 ព្រះអង្គមានបន្ទូល "បើសិនជានាងស្គាល់ថា នរណាដែលនាងកំពុងនិយាយជាមួយ នាងនឹងសុំទឹកពីខ្ញុំផឹកវិញ។" ការសន្ទនាបន្ត។ ព្រះអង្គមានបន្ទូល "ទៅហៅប្តីនាងមកទីនេះមក។"

នាងនិយាយ "ខ្ញុំគ្មានប្តីទេ។"

ព្រះអង្គមានបន្ទូល "អ្នកនិយាយត្រូវហើយ ព្រោះនាងមានបុរសប្រាំនាក់។"

នាងនិយាយ "ចាស លោក!"

85 ចូរមើលភាពខុសគ្នារវាងការនោះនិងពួកគេ—និងពួកសង្ឃនៅសម័យនោះ ដែលជាពួកក្រុមប្រឹក្សារស់នៅក្នុងពន្លឺសម័យផ្សេង។ ពួកគេនិយាយថា "នេះជាអារក្ខ!" ពួកគេត្រូវឆ្លើយតបនឹងក្រុមជំនុំពីអ្វីមួយ ព្រោះវាតម្រូវឱ្យធ្វើបែបនោះ។

86 ប៉ុន្តែអ្វីដែលស្ត្រីតូចទាបម្នាក់នេះ ថាពូជដែលតម្រូវទុកនៅក្នុងចិត្តរបស់នាង... នាងមិនចូលចិត្តហើយមានភាពនឿយហត់ចំពោះរឿងទាំងនោះ នាងត្រូវទៅតាមផ្លូវហើយធ្វើជាពេស្យាចារ។ ប៉ុន្តែពេលនាងឃើញរឿងនោះ នាងនិយាយ "លោក ខ្ញុំ

ដឹងថាលោកជាហោរ៉ា។ យើងមិនមានហោរ៉ាណាមួយ៤រយឆ្នាំហើយ ហើយយើងត្រូវបានប្រាប់មកថាពេលព្រះមេស៊ីយាងមក នោះជាអ្វីដែលព្រះអង្គនឹងធ្វើ។" អូ មែនហើយ! គ្រាប់ពូជ ដែលដាក់ចុះបានក្លាយជាមានជីវិតវិញ! ហេតុអ្វី? វាមិនត្រូវការការបកស្រាយទេ។

87 ព្រះយេស៊ូមានបន្ទូល "ខ្ញុំគឺជាព្រះអង្គនោះហើយ ដែលកំពុងតែមានបន្ទូលជាមួយអ្នក។" ទ្រង់បានធ្វើការអស្ចារ្យ និង ធ្វើទីបន្ទាល់ពីអង្គទ្រង់ថាជាព្រះមេស៊ី អាម៉ែន ហើយមានលក្ខណៈដូចបានកត់ត្រាទុកពីអ្វីដែលព្រះជាម្ចាស់បានសន្យា ("ព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងតាំងឱ្យមានព្យាការីដូចជាខ្ញុំ" ម៉ូសេនិយាយ)។ វាជាអ្វី? ជាការកាត់សេចក្ដីនៃខគម្ពីរ!

88 នាងរត់ចូលទៅក្នុងទីក្រុងហើយនិយាយ "មក មកមើលមនុស្សដែលប្រាប់ខ្ញុំពីរឿងដែលខ្ញុំបានធ្វើ។ តើនេះមិនមែនជាព្រះគ្រិស្ដទេឬអី? តើនេះមិនមែនជាទ្រង់ទេឬ? ទ្រង់បានប្រាប់ខ្ញុំពីអ្វីដែលខ្ញុំបានធ្វើ។"

89 ឥឡូវចូរសម្គាល់ ព្រះយេស៊ូជាអង្គដែលយាងមកដោយភាពជាមនុស្ស ហើយបានបែខ្នងទ្រង់ទៅតង់ជំរុំ ហើយប្រាប់ពីសារ៉ាដែលគាត់កំពុងតែគិតអ្វីនៅក្នុងជំរុំតង់។

90 ព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានបន្ទូល ក្នុងគម្ពីរហេព្រើ ជំពូក៤ថា...ព្រះអង្គមានបន្ទូលបែបនេះ "ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានអំណាចជាងដាវមុខពីរ កាត់ផ្ដាច់ទាំងសន្លាក់ឆ្អឹងអស់ទាំងគំនិតដែលត្រិះនៅក្នុងចិត្ត។"វាជាព្រះបន្ទូល! ហើយគ្រប់ពេលដែលព្យាការី មកគាត់មកជាមួយ ព្រះបន្ទូលហើយគាត់ជាព្រះបន្ទូលសម្រាប់សម័យនោះ។ តើព្រះបន្ទូលនឹងធ្វើអ្វី? អ្នកថ្លែងទំនាយ ស្គាល់គំនិតដែលនៅក្នុងចិត្ត។

91 វាបានធ្វើឡើងនៅក្នុងព្រះយេស៊ូគ្រិស្ដ ព្រោះព្រះអង្គគឺជាសេចក្ដីពោរពេញនៃព្រះបន្ទូល។

92 ព្រះយេស៊ូមានបន្ទូលថា "កូនមនុស្សនឹងបានមកដូចជាថ្ងៃនៅក្រុងសូដុំដែរ"។ វិញ្ញាណរបស់ព្រះជាម្ចាស់នឹងបានយាងមកក្នុងទម្រង់ជារាងកាយរបស់មនុស្ស ជាព្រះជាម្ចាស់ដែលបានបង្ហាញក្នុងទម្រង់សាច់ឈាមរបស់មនុស្ស។ (អាម៉ែន! តើអ្នកឃើញទេ?) ហើយអាចធ្វើដូចគ្នាជាមួយអ្វីដែលព្រះជាម្ចាស់បានធ្វើក្នុងភាព ជា

មនុស្សនៅក្នុងក្រុងសូដុំ។ សូមចងចាំ ពួកគេកំពុងតែរង់ចាំ កូននៃសេចក្តីសន្យាដែលមក។ នោះជាទីសម្គាល់ចុងក្រោយសម្រាប់ក្រុងសូដុំ និងក្រុមមនុស្សរបស់អ័ប្រាហាំឃើញ មុនកូននៃសេចក្តីសន្យាបានមកដល់។ តើអ្នកកត់សម្គាល់បែបនេះទេ? តើឥឡូវក្រុមជំនុំខាងវិញ្ញាណបានមកនៅពេលនោះ។

93 មានអ្នកនិយាយ "បងប្រុសប្រានហាំ តើអ្នកនិយាយថា 'គឺជាព្រះជាម្ចាស់'?"

94 ព្រះគម្ពីរបាននិយាយ គឺជាព្រះហើយ! វាមិនត្រូវការការបកស្រាយទេ។ ព្រះអង្គជា អេឡូហ៊ីម។ នោះជាឈ្មោះ អ័ប្រាហាំហៅនាមទ្រង់។ អ្នកអានព្រះគម្ពីរស្គាល់ពាក្យនេះ។ *អេឡូហ៊ិម* "អង្គដែលមានភាពគ្រប់ទាំងអស់។" ព្រះអង្គជាដើមដំបូងជាចុងក្រោយ ជាទីចាប់ផ្តើម និង ជាទីបញ្ចប់។ អេឡូហ៊ីម! អ័ប្រាហាំហៅទ្រង់"អេឡូហ៊ីម។" ព្រះជាម្ចាស់(នៅក្នុងអក្សរធំ ភាសាហេព្រើ) អេឡូហ៊ីមដូចជាពីដើមដំបូង "ព្រះជាម្ចាស់" អេឡូហ៊ីម។

95 ព្រះអង្គជា អេឡូហ៊ីម ដែលបើកសម្តែងក្នុងសាច់ឈាមជាមនុស្ស ស្លៀកសម្លៀកបំពាក់មនុស្ស សោយអាហាររបស់មនុស្ស។ អាម៉ែន! សញ្ញាសម្គាល់ចុងក្រោយដែលព្រះជាម្ចាស់នឹងលេចមកម្តងទៀតក្នុងចំណោមរាស្ត្ររបស់ទ្រង់នៅក្នុងសាច់ឈាមជាមនុស្ស! អាម៉ែន! ព្រះយេស៊ូមានបន្ទូល "កិច្ចការដែលខ្ញុំបានធ្វើអ្នករាល់គ្នាក៏អាចធ្វើបានដែរ។ ហើយដូចជាថ្ងៃនៅក្រុងសូដុំយ៉ាងណា កូនមនុស្សក៏មកបែបជាយ៉ាងនោះដែរ។" អាម៉ែន! នោះមិនចាំបាច់មានការបកស្រាយឡើយ វាត្រូវការការបើកសម្តែង នូវអ្វីដែលត្រូវការ។ អាម៉ែន។ តើអ្នកជឿទេ?

សូមឱនក្បាល។

96 ព្រះវរបិតាគង់នៅស្ថានសួគ៌ ទូលបង្គំសូមថ្វាយ ការសន្យារបស់ទ្រង់នៅយប់នេះដែលព្រះអង្គមានបន្ទូលពីសេចក្តីនេះ។ ព្រះអង្គសន្យាជាមួយពួកគេ។ គ្មាននរណាម្នាក់ធ្វើឱ្យព្រះបន្ទូលទ្រង់មានជីវិត លើកលែងតែទ្រង់មួយអង្គប៉ុណ្ណោះ។ ព្រះអង្គមានបន្ទូល "ចូរមានពន្លឺ" នោះក៏មានពន្លឺ។ គ្មាននរណាបកស្រាយឡើយ។ វាជាការបើកសម្តែង។

97 ពេលយើងដកស្រង់ចេញពីអេសាយ ដែលជាព្យាការី "ស្ត្រីក្រមុំព្រហ្មចារីនឹងមានគភ៌" នាងក៏មានមែនមិនចាំបាច់បើកសម្តែងឡើយគឺនាងមានមែន។ នោះជាអ្វីដែលបានកើតឡើង។

98 ទ្រង់មានបន្ទូលពេលព្រះអង្គយាងមកព្រះអង្គប្រសូត្រនៅក្នុងភូមិបេថ្លេហិម "ចេញពីគឺបេថ្លេហិម ស្រុកយូដា។ តើអ្នកមិនមែនជាអ្នកដែលតូចជាងគេដែលជាមេនៃស្រុកយូដា នៅក្នុងស្រុកអ៊ីស្រាអែលទេឬ? ប៉ុន្តែនឹងមានអ្នកដឹកនាំរាស្ត្ររបស់យើងកើតចេញពីឯងមក។"

99 អ្វីដែលព្រះអង្គនឹងធ្វើ អ្វីដែលព្រះអង្គព្រះកន្សែងនៅលើឈើឆ្កាង និងតើទ្រង់ត្រូវកាត់ទោសជាយ៉ាងណាត្រូវបានគេកម្ទេចជើងនិងដៃព្រះអង្គ "ព្រះអង្គត្រូវរងទុក្ខដោយព្រោះការរំលងរបស់យើង និង រងស្នាមជាំដោយសារសេចក្តីរំលងរបស់យើងដែរ ការរងទារុណកម្មដើម្បីសេចក្តីសុខសាន្តរបស់យើងបានធ្លាក់ទៅលើព្រះអង្គដោយសារស្នាមរបួសរបស់ទ្រង់យើងបានជា។"

100 តើហេតុម្តេចបានជាដាវីឌ និយាយបានថា "យើងមិនទុកព្រលឹងអ្នកនៅក្នុងស្ថាននរកឡើយ ក៏នឹងមិនធ្វើឱ្យអ្នកបរិសុទ្ធរបស់យើង ឃើញសេចក្តីពុកផុយដែរ។" ហើយនៅថ្ងៃទីបី មុនចិតសិបពីរម៉ោង ដែលអាចនាំឱ្យរាងកាយរបស់គាត់ត្រូវពុកផុយ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានបន្ទូល "លោកនឹងរស់ឡើងវិញ។" (ពួកគេនិយាយថា មានគេលួចសាកសពយកទៅពួកគេនៅជឿថាដូច្នេះ។) ប៉ុន្តែយើងជឿ ព្រះអម្ចាស់ ព្រះបន្ទូលទ្រង់! វាត្រូវបានបើកសម្តែងឱ្យឃើញដូច្នេះ។ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយមានបន្ទូល "ខ្ញុំនឹង... មើលខ្ញុំនឹងនៅជាមួយអ្នកជានិច្ច ទោះដល់ថ្ងៃបញ្ចប់ពីភពលោកក៏ដោយ។"

101 យើងជឿថាព្រះអង្គគង់នៅយប់នេះ។ យើងជឿថាព្រះអង្គគឺជាព្រះយេស៊ូគ្រិស្តគង់នៅយប់នេះ នៅទីនេះ ដូចជាទ្រង់ធ្លាប់មានព្រះវត្តមាន។ ហើយព្រះអង្គទតរកមើលភ្នែក ដៃ ជើង មាត់ ព្រលឹង រាងកាយ ដែលទ្រង់អាចបង្ហាញអង្គទ្រង់ចេញមក។ ព្រះជាម្ចាស់ សូមព្រះអង្គបន្សុតទូលបង្គំនៅយប់នេះ ដែលទូលបង្គំអាចឃើញព្រះយេស៊ូគ្រិស្តដ៏មានព្រះជន្មនៅក្នុងចំណោមទូលបង្គំ។ សូមព្រះអង្គយាងមក! ដើម្បីនឹងបានឆ្លងកាត់ ដូចជាជនជាតិក្រិកដែលពួកគេស្រេកឃ្លានដូចនៅថ្ងៃនោះដែរ ហើយនិយាយថា "លោកម្ចាស់ យើងចង់ឃើញព្រះយេស៊ូ។" ហើយពួកគេអាចឃើញទ្រង់បាន។ អូ តើវាជាការរំភើបយ៉ាងណាពេលគេ មើលទៅកាន់ទ្រង់!

102 ព្រះជាម្ចាស់ ព្រះអង្គនៅតែដដែលនៅថ្ងៃនេះ។ ហើយសន្យាថា បើទូលបង្គំស្រេកឃ្លាន ទូលបង្គំនឹងបានឃើញព្រះអង្គ។ "បន្តិចទៀត ពិភពលោកគេមិនឃើញខ្ញុំទៀតទេ" (អ្នកមិនជឿ) "តែអ្នករាល់គ្នានឹងឃើញខ្ញុំ ព្រោះខ្ញុំនឹងនៅជា

មួយអ្នករាល់គ្នា នៅក្នុងអ្នករាល់គ្នាផង លុះដរាបចុងបញ្ចប់នៃផែនដី។″ ទូលបង្គំដឹងថាព្រះអង្គនៅដូចថ្ងៃថ្ងៃម្សិលមិញ ថ្ងៃនេះ និងជារៀងរហូតទៅ។

103 ព្រះអម្ចាស់ ព្រះបន្ទូលទ្រង់បានប្រាប់ថា មានសេចក្តីចែងទុកថា ឥឡូវចូរឱ្យបានសម្រេច សម្រាប់សិរីរុងរឿងរបស់ព្រះជាម្ចាស់ ដើម្បីបង្ហាញថាព្រះអង្គ រក្សាតាមព្រះបន្ទូលទ្រង់។ អាម៉ែន។ សូមព្រះប្រទានពរ។

104 ខ្ញុំនឹងហៅតាមជួរអធិស្ឋាន ។ ខ្ញុំជឿថាប៊ីលលីបានចែកកាតអធិស្ឋានរបស់យើងខ្ញុំ ពីលេខមួយដល់មួយរយ ឬអ្វីដែលស្រដៀងនោះ។ ឥឡូវគាត់មិននៅទីនេះទេ។ តើ...លេខកាតប៉ុន្មាន...មានអ្នកមើលនៅក្រោយខ្នងរបស់អ្នក...វានឹង—វាមានលេខ—មានអក្សរ (អេ ប៊ី ស៊ី ឌី ឬ...)។ វាជាអ្វី អេ? ត្រូវហើយ។

105 ចូរយក អេ លេខមួយ ពីរ បី បួន ប្រាំ។ ចូរឈរបែបនោះហើយ។ លេខមួយ លេខពីរ លេខបី លេខបួន។ លេខបួន ខ្ញុំមិនឃើញក្រោកឈរ។ កាតអធិស្ឋានលេខបួន។ មួយ ពីរ បី។ អធិស្ឋាន...ប្រហែលពួកគាត់មិនអាចក្រោកឈរបាន។ បើមិនអាចសូមឱ្យអ្នកក្រលេកមើលកាតអ្នកជិតខាង គាត់ប្រហែលមានកាត តែគាត់មិនអាចក្រោកឈរបាន។ សូមប្រញាប់ឡើង។ មានលេខបួន។ លេខប្រាំ កាតអធិស្ឋានលេខប្រាំ។ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់ ដប់មួយ ដប់ពីរ។ សូមចូលកន្លែងរបស់អ្នកនៅពេលគេហៅលេខរបស់អ្នក។ លេខមួយ ពីរ បី សូមមកតាមផ្លូវនេះ។ កាតលេខមួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់ ដប់មួយ សូមទៅកន្លែងអ្នក។ ដប់មួយ ដប់ពីរ ដប់បី ដប់បួន ដប់ប្រាំ ដប់ប្រាំមួយ ដប់ប្រាំពីរ ដប់ប្រាំបី ដប់ប្រាំបួន ម្ភៃ ម្ភៃមួយ ម្ភៃពីរ ម្ភៃបី ម្ភៃបួន ម្ភៃប្រាំ។ មានអ្នកណាមិនមានទេ...

106 ខ្ញុំឃើញ ក្មេងប្រុសនៅលើកៅអីខាងក្រោយ។ បើបានឮគេហៅលេខអ្នកហើយ កូនប្រុស ហើយ—ហើយបើអ្នកមិនអាចមករួច...ល្អ សូមបន្តលើកដៃ យើងនឹងឃើញថាអ្នកនៅកន្លែងនេះ។ ឃើញទេ?

107 ប៉ុន្មាននាក់នៅទីនេះដែលមិនមានកាតអធិស្ឋាន ហើយអ្នកឈឺដែរ? សូមលើកដៃឱ្យបានឃើញ នៅកន្លែងណាក៏បាន។ មកទីនេះ ត្រូវហើយ សូមលើកដៃឡើង។ តើអ្នកជឿទេ? ពេលអ្នកមកជុំគ្នា អ្នកជឿទេថា ព្រះអង្គនៅដូចថ្ងៃម្សិលមិញ និងរៀងរហូតទៅ? ប៉ុន្មាននាក់? ចូរមើលគ្រូគង្វាលទាំងនេះ តើខគម្ពីរមិនបាននិយាយនៅថ្ងៃនេះទេឬ បងប្អូន ថាព្រះអង្គជាមហាបូជាចារ្យ ដែលអាចយល់ពី

អារម្មណ៍ និង កំហុសរបស់យើងបាន? តើត្រូវទេ? តើប៉ុន្មាននាក់ដែលជឿបែប នោះ? តើប៉ុន្មាននាក់ដែលជឿ សូមលើកដៃ។ ព្រះអង្គជាមហាបូជាចារ្យ ដែលអាច យល់ពីអារម្មណ៍ និងកំហុសរបស់យើងបាន។

108 ដូច្នេះ បើព្រះគម្ពីរបាននិយាយ "ព្រះអង្គនៅដូចថ្ងៃម្សិលមិញ និងរៀង រហូតទៅ" តើមានប៉ុន្មានអ្នកដែលជឿដូច្នេះ? ដូច្នេះតើព្រះអង្គ នឹងធ្វើអ្វីនៅ ថ្ងៃនេះ? ព្រះអង្គនឹងប្រព្រឹត្តដូចម្សិលមិញដែរ។ តើត្រឹមត្រូវទេ? តើយប់នេះព្រះអង្គ នៅឯណា? ព្រះអង្គគង់នៅខាងស្តាំនៃព្រះដ៏មានព្រះចេស្តា ព្រះកាយទ្រង់ និង ព្រះវិញ្ញាណរបស់ព្រះអង្គនៅទីនេះក្នុងអារគានេះ ដើម្បីបង្ហាញអង្គទ្រង់។

109 ចូរកត់សម្គាល់ ឥឡូវពិនិត្យមើល។ តើមានអ្វីកើតឡើងពេលមាននរណាម្នាក់ ពាល់អាវរបស់ព្រះអង្គនៅពេលនោះ មានស្ត្រីម្នាក់ពេលនោះ? នាងមិនមានកាត អធិស្ឋានឡើយ យើងអាចនិយាយដូច្នេះ ប៉ុន្តែនាងបានពាល់អាវរបស់ព្រះអង្គ។ ពេលនាងពាល់អាវរបស់ទ្រង់ព្រះយេស៊ូងាកបែរមកនិងមានបន្ទូលថា "នរណា ប៉ះខ្ញុំ?"

110 ពេត្រុសបន្ទោសទ្រង់និងនិយាយ "ហេតុអ្វី ព្រះអម្ចាស់អើយ ដែលស្តាប់ទៅ ដូចជាមិនសមហេតុផល។ ហេតុអ្វី ព្រោះមានមនុស្សគ្រប់គ្នាគេព្យាយាមមកប៉ះ ទ្រង់។ ហេតុអ្វីព្រះអង្គមានបន្ទូលថា 'នរណាប៉ះខ្ញុំ?'"

111 ព្រះអង្គមានបន្ទូល "ប៉ុន្តែខ្ញុំដឹងថាខ្ញុំចុះខ្សោយជាងមុន។" តើមនុស្សប៉ុន្មាន នាក់ដែលដឹងដូច្នោះ? *ជាគុណធម៌* ដែលមានន័យថា "កម្លាំង" ដែលចេញពី ព្រះអង្គទៅ។ "ខ្ញុំចុះខ្សោយ មានអ្នកប៉ះដល់ខ្ញុំដោយរបៀបប៉ះខុសគេ។" ហើយ ព្រះអង្គក៏ងាកមក និងមើលទៅកាន់ហ្វូងមនុស្សរហូតដល់ព្រះអង្គអាចរកឃើញ បណ្តាញភ្ជាប់ជំនឿនោះ។

112 គ្រប់គ្នាដាក់ដៃជុំវិញព្រះអង្គ "អូ លោកគ្រូ ទូលបង្គំជឿព្រះអង្គ" និង ទាំងអស់គ្នាបែបនេះ។

113 ប៉ុន្តែមានអ្នកខ្លះ ពិតជាខ្លាំងណាស់។ នាងពាល់នឹងអាវរបស់ព្រះអង្គដោយ ជឿថានាងនឹងបានជា ព្រោះនាងបាននិយាយនៅក្នុងចិត្តនាងថា បើសិនជានាង គ្រាន់តែធ្វើរឿងនោះប្រាកដជាកើតឡើង។

114 នាងបែរមករួចមើលទៅហ្វូងមហាជនរហូតដល់ព្រះអង្គរកនាងឃើញ រួចព្រះអង្គមានបន្ទូល...ប្រាប់នាងថាជំងឺធ្លាក់ឈាមរបស់នាងបានឈប់ និងបានជាពិតមែន។ តើនោះត្រឹមត្រូវឬទេ? ឥឡូវនេះជារបៀបដែលព្រះអង្គធ្វើ នៅក្នុងបណ្ដាជន។

115 ឥឡូវ ខ្ញុំប្រកាសថា ព្រះអង្គមិនសុគតឡើយ ព្រះអង្គមានព្រះវត្តមាននៅថ្ងៃនេះ ដូចជាព្រះអង្គពីមុនដែរ។ ហើយព្រះគម្ពីរបានប្រាប់ថា ព្រះយេស៊ូមានបន្ទូលពីព្រះអង្គ "ថ្ងៃនៅក្នុងក្រុងសូដុំយ៉ាងណា ពេលបុត្ររបស់មនុស្សមកវិញក៏យ៉ាងនោះដែរ។"

116 ឥឡូវមើល មិនថាព្រះជាម្ចាស់មានអំណោយទានយ៉ាងណានៅសម័យនោះទេ ត្រូវតែមានម្នាក់នៅទីនោះ ផងដែរ ដើម្បីទទួលខុសត្រូវ។ ព្រះអង្គយាងចូលទៅទីក្រុង ព្រះគម្ពីរបានប្រាប់ថា "មានរឿងជាច្រើនដែលព្រះអង្គមិនបានធ្វើ ព្រោះចិត្តមិនជឿរបស់ពួកគេ។" តើនោះត្រឹមត្រូវឬទេ? ដូចជាបច្ចុប្បន្នដែរ។ អ្នកត្រូវតែជឿដល់ព្រះអង្គ។ នោះជារបៀបតែមួយដែលអ្នកអាច។

117 តើអ្នកអធិស្ឋានរៀបចំរួចរាល់ឬនៅ? ឥឡូវ សូមទាំងអស់គ្នាផ្ដល់ការគោរពសម្រាប់ពេលដប់នាទី។ មិនដឹងថាខ្ញុំអាចធ្វើវាបានឬអត់ ខ្ញុំគិតថាម្ភៃប្រាំនាទី ឬសាមសិបនាទីដើម្បីឈរនៅទីនោះ។ ប៉ុន្តែឥឡូវ ក្នុងជួរអធិស្ឋាន បងប្អូនម្នាក់ៗនៅតាមជួរអធិស្ឋានដឹងហើយថាខ្ញុំជាមនុស្សថ្មីចំពោះអ្នករាល់គ្នា ខ្ញុំមិនដឹងរឿងអ្វីពីបងប្អូនដែរ សូមលើកដៃ។ បងប្អូនម្នាក់ៗដែលនៅតាមជួរអធិស្ឋាន។

118 ឥឡូវចំពោះអ្នកចូលរួម ដឹងថាខ្ញុំមិនស្គាល់បងប្អូនទេ សូមលើកដៃ។ ឥឡូវឥឡូវ នេះជាអ្វីដែលខ្ញុំព្យាយាមនិយាយ មិត្តសម្លាញ់អើយ សូមមើល។ ឥឡូវនៅទី នេះ។ មានចាស់ទុំអ្នកដឹកនាំនៅទីនេះលើ វេទិកា។ ហើយព្រះគ្រិស្តធ្វើការសន្យានេះ។ មើល មានសរសេរទុកមក។ តើវាត្រូវសម្រេចពេលណា? នៅថ្ងៃចុងក្រោយមុនថ្ងៃព្រះអម្ចាស់យាងមក។ តើត្រូវទេ? វានឹងសម្រេចឡើង។

119 ឥឡូវ មានព្រះបន្ទូលដែលថ្លែងនៅថ្ងៃនេះ។ មិនមែនសម័យពន្លឺលូធឺ មិនមែនពន្លឺរបស់វេស្លី ក៏មិនមែនជាពន្លឺនៃពេនទីកុស្ដដែរ។ វាកន្លងផុតទៅហើយ។ ឥឡូវលូធឺក៏មិនអី មេតូឌីស្ដក៏មិនជាអ្វី បាបទីស្ដក៏មិនជាអ្វី ទាំងអស់គ្នា ទាំងពេនទីកុស្ដសុទ្ធតែមិនមានបញ្ហា។ មានគ្រប់សាវតាដែលអង្គុយនៅទីនេះនៅយប់នេះ។ តើវាមិន—វាមិន—វាមិនមានភាពឯកជនទេ។ ចុះបើ...

120 អ្នកមិនអាចប្រាប់អ្នកមេតូឌីស្តពីសេចក្ដីមកពីលូធីឡើយ ព្រោះគេជឿលើការធ្វើឱ្យវិសុទ្ធ កាលបើអ្នកលូធី មិនជឿទេ ។ ឃើញទេ?

121 អ្នកមិនអាចប្រាប់ អ្នកពេនទីកុស្តពី "ការធ្វើឱ្យវិសុទ្ធពីរឿងនោះឡើយ" គាត់បានឃើញនូវការស្តារឡើងវិញនៃអំណោយទាននោះ។ គាត់មិនជឿរឿងនោះទេ។ទេ គាត់មានអ្វីដែលច្រើនជាងនោះ។ ឃើញទេ? ហើយនោះជាសម័យក្រុមជំនុំចុងក្រោយដែលយើងមាន ហើយព្រះគម្ពីរប្រាប់ថានឹង គ្មានសម័យក្រុមជំនុំទៀតឡើយ។

122 ប៉ុន្តែ នឹងមានការជួបជុំមនុស្ស ឃើញទេ ហើយយើងនៅត្រង់នេះ។ ឥឡូវ សូមចាំ ជាសញ្ញាទីសម្គាល់ចុងក្រោយ។ តើយើងជាមនុស្សដែលរង់ចាំបុត្រសន្យា រឺ? សូមលើកដៃរបស់អ្នក។ តើអ្នកជឿថាអ្នកជាពូជរបស់អ័ប្រាហាំតាមរយៈព្រះគ្រិស្ត? សូមលើកដៃ។ ដូច្នេះ ពូជរបស់អ័ប្រាហាំអើយ ទទួលយកទីសម្គាល់របស់អ្នកចុះ! តើនេះមិនមែនជាការនៅក្រៅបាប៊ីឡូនទេឬ តើនេះមិនមែននៅខាងក្រៅ និកាយរបស់ពិភពលោកទេឬ?តើនៅក្នុងចំណោមអ្នករាល់គ្នាមិនមែនជាអ្នក ដែល ចេញពីភាពរញ៉េរញ៉ៃនោះទេឬ។ សូមជឿចុះ!

123 នៅទីនេះមានស្ត្រីម្នាក់ គាត់ជាមនុស្សថ្មីសម្រាប់ខ្ញុំ ប្រហែលអាយុស្របាលគ្នា។ ខ្ញុំមិនដែលជួបគាត់ពីមុនទេនៅក្នុងជីវិតខ្ញុំ។ បើខ្ញុំអាចព្យាបាលស្ត្រីនេះបាន ខ្ញុំនឹងធ្វើវា បើសិនជាគាត់ឈឺ។ ខ្ញុំមិនដឹងរឿងអ្វីពីគាត់ឡើយ។ តើអ្នកឃើញគាត់ដែលបានលើកដៃ ពីរបីនាទីមុននោះទេ។ ខ្ញុំ—ខ្ញុំមិនធ្លាប់ជួបគាត់ទេ។ គាត់ជាស្ត្រីម្នាក់ឈរនៅទីនោះ។

124 ថ្ងៃនេះ ពួកគេមកទីនេះ យកមកជាមួយនូវកាតអធិស្ឋានមួយដុំ លាយគ្នារួចចែកដល់មហាជន។ មានម្នាក់បានលេខមួយនៅទីនេះ និងលេខដប់នៅខាងក្រោយ លេខដប់ប្រាំ ដប់ប្រាំពីរ លេខ...បែបនោះ។ ពួកគេលាយគ្នានៅចំពោះមុខអ្នករាល់ថ្ងៃ។ ហើយពេលពួកគេហៅ ពួកគាត់ក៏ហៅមកពីគ្រប់កន្លែង។ ឃើញទេ? ហើយ ឥឡូវ អ្នកមិនចាំបាច់មានកាតអធិស្ឋានទេ គ្រាន់តែអង្គុយនៅទីនេះ ហើយអធិស្ឋាន និងជឿចុះ។ ហេតុអ្វីមិនអាច...

125 សូមរំលឹកខ្លួនឯងនៅយប់នេះ ស្វែងរកសម័យកាលដែលយើងកំពុងរស់នៅ។ ឃើញទេ? ឥឡូវវាហួសហើយសម្លាញ់។ វាជិតផុតហើយ!

126 ឥឡូវ បើសិនជាព្រះនៃអ័ប្រាហាំ ប្រោសឱ្យព្រះយេស៊ូគ្រិស្តរួចពីសុគត ហើយ ព្រះយេស៊ូសន្យាថាថ្ងៃចុងក្រោយដែលមានទីសម្គាល់ដូចគ្នាដែលអ័ប្រាហាំ...ថា ទេវតា (ដែលជាព្រះគង់ក្នុងសាច់ឈាមជាមនុស្ស) បានសម្រេចនៅមុខអ័ប្រាហាំ មុនពេលដែលកូននៃសេចក្ដីសន្យាមកដល់ ព្រះយេស៊ូមានបន្ទូលថានឹងមានអ្វី កើតឡើងដូចគ្នានៅបច្ចុប្បន្ន។

127 ឥឡូវយើងឃើញ អាតូមិក និង និកាយ និង អ្វីទាំងអស់ ហើយ និងភាព ឥតប្រយោជន៍ដែលគេមាន។ យើងឃើញ ប៊ីលលីហ្រ្គាហាំ នៅត្រើយម្ខាង និង អូរ៉ល រ៉ូប៊ឺត និងពួកគេនៅទីនោះ អ្នកនាំសាររបស់ពេនទីកុស្ត និង អ្នកនាំសារ និកាយ បន្ត មកយើងឃើញសេចក្ដីទាំងអស់តមក នាំមកជាមួយទីសម្គាល់។ ប៊ី លលី ហ្គ្រាហាំ ជាអ្នកទេវៈវិទូសម្រាប់ចំណុចមួយអ្វីដែលនិកាយគេជឿ។ អូរ៉លរ៉ូប៊ឺត ជាអ្នក ប្រោស ឱ្យជាសម្រាប់ចំណុចនោះ ដូចអ្វីដែលជាពេនទីកុស្ត...

128 ប៉ុន្តែមើលនៅទីនេះមានអ្វីមួយទៀតដែលត្រូវបានសន្យាថាជាពូជរបស់អ័ប្រា ហាំ។ ពួកគេចុះមកក្នុងចំណោមនិកាយផ្សេងៗ មានអ្វីមួយ *ចេញ* ពីនិកាយដែល ត្រូវកើតឡើង ប្រមូលមនុស្ស។ យើងនឹងទុកឱ្យវាបន្តរហូតដល់យប់ថ្ងៃស្អែក។

129 មើល ខ្ញុំមិនស្គាល់ស្ត្រីនោះទេ។ ខ្ញុំបែរខ្នងដាក់គាត់។ បើព្រះអម្ចាស់ជា ព្រះជាម្ចាស់នឹងមានបន្ទូលអ្វីពីស្ត្រី អាចជា—ជារឿងក្នុងផ្ទះ អាចជារឿងហិរញ្ញវត្ថុ ឬ ជំងឺ ខ្ញុំមិនដឹងទេ។ គាត់នឹងដឹងថាពិតឬមិនពិត។

130 បើសិនជាព្រះអង្គធ្វើការនៅយប់នេះ ដូចជាព្រះអង្គបានធ្វើពីមុន តើអ្នកជឿ ព្រះជាម្ចាស់ដែលព្រះយេស៊ូ សន្យាថានឹងគង់នៅទីនេះនៅថ្ងៃចុងក្រោយឬទេ? តើប៉ុន្មាននាក់ដែលជឿថាយើងកំពុងរស់នៅដូចជាក្រុងសូដុំ ពេលពិភពលោក ទាំងមូលឈានទៅក្នុងស្ថានភាពក្រុងសូដុំ? តើអ្នករាល់គ្នាប៉ុន្មាននាក់ជឿ អ្វីដែល ខ្ញុំបានប្រាប់នៅយប់នេះថាជាសេចក្ដីពិត? បន្ទាប់មក កូនៗដែលជាគ្រាប់ពូជរបស់ អ័ ប្រាហាំ ជឿដល់ព្រះជាម្ចាស់!

131 ឥឡូវសូម កុំគិតថាខ្ញុំកំពុងព្យាយាមនិយាយជាមួយស្ត្រីពីអ្វីមួយ ដោយសម្លឹង មើលមុខនាង ឬ អាចទទួលបានអ្វីមួយតាមរយៈទូរចិត្ត ឬ អ្វីមួយដែលអ្នកចង់ ដឹង។ អ្នកដែលដឹងមុន ទូរចិត្តនឹងអាចធ្វើបានច្រើនជាងនោះផង។ ឃើញទេ? ឃើញ ទេ? តើអ្នកធ្លាប់ឃើញអ្នកទូរចិត្តវិទូ អធិប្បាយដំណឹងល្អឬទេ? តើអ្នកធ្លាប់

ឃើញអ្នកខាងវិញ្ញាណអធិប្បាយដំណឹងល្អ ធ្វើទីសម្គាល់ និង ការអស្ចារ្យ ប្រកាសពីព្រះយេស៊ូដូចគ្នាឬទេ? ទេ។

132 ឃើញទេ វាគ្រាន់តែជា...វាជាគំនិតរបស់មនុស្ស។ ឃើញ ពួកគេងងឹត។ តើអ្នកជឿទេថាពួកគេអាចងងឹត? ព្រះគម្ពីរប្រាប់ថាពួកគេពិតជាអាច។ ត្រូវទេ? "មិនស្រឡាញ់តាមធម្មតាមនុស្ស គ្មានសេចក្តីអធ្យោគ និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្តសាហាវ មិនចូលចិត្តនឹងការល្អ ក្បត់គេ ឥតបើគិត មានចិត្តធំ ហើយចូលចិត្តនឹងល្បែងលេងជាជាងព្រះ គេមានឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ ប៉ុន្តែមិនព្រមទទួលស្គាល់ព្រះចេស្តា ដែលមកដោយការគោរពប្រតិបត្តិនោះទេ ចូរបែរពីពួកមនុស្សយ៉ាងនោះចេញ។"

133 ព្រះយេស៊ូមិនបានមានបន្ទូលទេឬអីនៅក្នុង ម៉ាថាយ២៤:២៤ "ដ្បិតនឹងមានព្រះគ្រីស្ទក្លែងក្លាយហើយហោរាក្លែងក្លាយកើតឡើងគេនឹងធ្វើទីសំគាល់ យ៉ាងធំ ហើយ និងការអស្ចារ្យ ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឲ្យវង្វេងផង បើសិនជាបាន"? ប៉ុន្តែវាមិនអាចទៅរួចឡើយ។ ពួកវាស្ថិតនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ តាំងពីដើមដំបូងមក ហើយជាផ្នែកមួយនៃព្រះជាម្ចាស់។

134 ឥឡូវ ព្រះនៃអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប សូមឱ្យបានស្គាល់នៅយប់នេះ ដែលទូលបង្គំនឹងថ្លែងប្រាប់សេចក្តីពិតអំពីព្រះអង្គ។ គឺជាព្រះអង្គហើយព្រះអម្ចាស់។ ដោយបន្ទាបខ្លួន សូមឱ្យអ្នកបម្រើព្រះអង្គអាចយកគំនិតរបស់ខ្លួនចេញពីផ្លូវ ដែលព្រះអង្គអាចប្រើរាងកាយរបស់ទូលបង្គំទាំងអស់ សម្រាប់សិរីរុងរឿងរបស់ព្រះអង្គ។ ដោយព្រះនាមព្រះយេស៊ូ ព្រះបុត្រារបស់ព្រះជាម្ចាស់។ អាម៉ែន។

135 អ្វីទៅជាអំណោយទាន? មិនមែនជាអ្វីដែលអ្នកយក កាត់ហើយត្រឡប់នោះ ទេ។ ទេ ទេ។ វាជារបៀបដែលស្គាល់ក្នុងការដកខ្លួនអ្នកចេញពីផ្លូវ ហើយព្រះជាម្ចាស់អាចប្រើ អ្នកបាន។ អំនោយទានគឺការដកខ្លួនអ្នកចេញ ហើយព្រះជាម្ចាស់អាចប្រើបាន។

136 ស្ត្រីដែលនៅពីក្រោយខ្ញុំគាត់នឹងស្លាប់ បើគាត់មិនជា។ ស្ត្រីដែលនៅពីក្រោយខ្ញុំទើបតែត្រូវបានអធិស្ឋានឱ្យដោយបុរសម្នាក់ផ្សេងទៀត ថ្មីៗនេះ។ គាត់មានជំងឺមហារីក។ មហារីកស្ថិតក្នុងសុដន់ និងសួតរបស់គាត់។ ហើយគាត់ទើបតែបានអធិស្ឋានសម្រាប់ជំងឺនោះ ហើយគាត់ព្យាយាមទទួលដោយជំនឿ រួចក៏បាន

ជា។ **នោះ ជាព្រះបន្ទូលរបស់ព្រះអម្ចាស់!** នោះជាការពិតទេ អ្នកស្រី? [ស្ត្រីនិយាយ "ចាស វាជាការពិត"—Ed។] បើដូច្នេះ គ្រី—គ្រវីដៃទៅកាន់អ្នកចូលរួម។ ព្រះជាម្ចាស់របស់អ័ប្រាហាំនៅមានព្រះជន្មនៅឡើយ! ត្រូវទេ ចូរជឿចុះ អ្វីដែលអ្នកជឿអ្នកនឹងបានជា។ អាម៉ែន។

អ្នកជឿ? អ្នកនិយាយ "ចុះអ្នកចូលរួមវិញ?"

137 ស្ត្រីម្នាក់នេះជាស្ត្រីដែលអង្គុយជាមួយគាត់...នៅចុងនៃជួរ ស្ត្រីទីពីរនៅទីនោះ។ ពេលខ្ញុំបែខ្លួនខ្ញុំឃើញរឿងមួយ នៅជុំវិញដៃរបស់គាត់ មានសម្ពាធឈាម។ គាត់មានជំងឺលើសឈាម។ តើត្រូវទេ អ្នកស្រី? សូមលើកដៃរបស់អ្នក។ បើអ្នកជឿ ជំងឺលើសឈាមនឹងបាត់ទៅ។ ព្រះរបស់អ័ប្រាហាំនៅមានរូបរាងនៅឡើយ។ ព្រះអង្គ នៅដូចពីមុនដែរ ជាព្រះបន្ទូលសម្រាប់ថ្ងៃនេះ!

138 តើអ្នកសុខសប្បាយជាទេ? អ្នកជឿទេឥឡូវ? សូមមានជំនឿដល់ព្រះជាម្ចាស់! ឱ្យដូចជាកូនក្មេង ព្រះជាម្ចាស់ជ្រាបពីចិត្តរបស់បងប្អូន ប្អូនស្រី ខ្ញុំមិនយល់ឡើយ។ តើអ្នកជឿទេថា ព្រះជាម្ចាស់អាចបើកសម្តែងដល់ខ្ញុំថាមានអ្វីដែលមិនស្រួល? តើអ្នកជឿព្រះអង្គថាខ្ញុំអាចទេ? វាមិនមែនសម្រាប់អ្នកទេ គឺសម្រាប់អ្នកផ្សេងទៀត នោះជាបងប្អូនប្រុសរបស់អ្នក។ គាត់មានសភាពធ្ងន់ធ្ងរ ហើយគាត់នៅក្នុងក្រុងខាងជើងទីនេះ ទូលា(Tulare)។ ហើយគាត់នៅក្នុងមន្ទីរពេទ្យហើយគាត់មានជំងឺឈាមសរសៃឈាមក្រហម ហើយដុកទ័របោះបង់គាត់ទុកចោលឱ្យស្លាប់ហើយ។ ព្រោះគ្មានសង្ឃឹមឡើយ។ គឺត្រូវបែបនោះហើយ។តើអ្នកជឿទេ? [ស្ត្រីនោះយំនិយាយថា "ចាស។"—Ed។] ត្រឹមត្រូវហើយ។ អ្វីដែលអ្នកមាននៅក្នុងដៃ? យកវាដាក់លើគាត់។ ហើយកុំសង្ស័យ។ សូមជឿ! អាម៉ែន។

139 តើអ្នកជឿទេ? ខ្ញុំមិនដែលជួបអ្នកស្រីនោះក្នុងជីវិតនេះទេ។ ប៉ុន្តែព្រះជាម្ចាស់ព្រះអង្គនៅតែជាព្រះ! ឥឡូវ ប្រាប់ខ្ញុំមកមនុស្សមិនអាចធ្វើការនោះបានឡើយ? តើមិនមែនមនុស្សទេឬដែលអាចធ្វើបាន។ គឺជាព្រះជាម្ចាស់ដែលព្រះយេស៊ូមានបន្ទូលសន្យាថានឹងមាននៅសម័យនេះនៅថ្ងៃចុងក្រោយដែលកាត់សេចក្តីបង្ហាញពីព្រះអង្គផ្ទាល់(ដូចជាមុនពូជរបស់អ័ប្រាហាំ) ដូចជាថ្ងៃនៅក្រុងសូដុំ។

140 ឥឡូវនៅទីនេះ ខ្ញុំមិនស្គាល់ស្ត្រីនេះទេ យើងសុទ្ធតែអ្នកចម្លែកថ្មីចំពោះគ្នាទៅ វិញទៅមក ខ្ញុំគិតថាជាលើកទីមួយក្នុងជីវិត។ តើអ្នកជឿខ្ញុំថាជាអ្នកបម្រើរបស់ព្រះឬទេ?[ស្ត្រីនិយាយថា"ចាស។"—Ed។] តើអ្នកជឿថានេះជាព្រះបន្ទូល

ទេ?[ "ចាស"] ហើយ អ្នកដឹងហើយថាប្រសិនបើ...ព្រះបន្ទូលនេះអាចជ្រាបពីគំនិត និង បំណងចិត្ត។ តើត្រូវទេ?[ "ត្រូវហើយ"] ព្រះបន្ទូលជាអង្គប្រោសឱ្យជាផងដែរ បើអ្នកអាចជឿ។ តើអ្នកជឿទេ? អ្នកត្រូវគ្របដោយស្រមោល ផងដែរ ជាស្រមោលខ្មៅ។ វាជាជំងឺមហារីក។ តើអ្នកជឿថាព្រះជាម្ចាស់អាចមានបន្ទូលប្រាប់ខ្ញុំពីទីតាំងរបស់ជំងឺមហារីកទេ? វាគឺនៅខាងក្រោមពោះវៀន ដុកទ័រនិយាយថាដូច្នេះ។ តើអ្នកជឿថាអ្នកនឹងជាឬទេ?[ "អាម៉ែន"] ទៅ ហើយកុំសង្ស័យឲ្យសោះ ហើយព្រះនឹងព្យាបាលអ្នកឲ្យជា។ អាម៉ែន។

141 អ្នកជឿទេ គ្រប់គ្នា? ដូចអ្វីដែលទ្រង់បានសន្យាថានឹងធ្វើ! ចូរមានជំនឿក្នុងព្រះជាម្ចាស់ កុំសង្ស័យ។

142 យើងជាមនុស្សចម្លែករវាងគ្នានឹងគ្នា។ ខ្ញុំមិនស្គាល់អ្នកទេ។ បើសិនជាយើងមិនដែលស្គាល់គ្នាសូមឱ្យអ្នកចូលរួមគេដឹងផង យើងចាប់ដៃ។ ខ្ញុំមិនដែលជួបស្ត្រីនេះ ក្នុងជីវិតខ្ញុំឡើយ។

143 តើអ្នកជឿទេ? អ្នកជឿថាគឺជាព្រះយេស៊ូគ្រិស្តទេ? វាជាអ្វី? គឺជាព្រះបន្ទូលព្រះអង្គ។ពេលមនុស្សទាំងនេះបដិសេធវាពួកគេមិនមែនបដិសេធមនុស្សឡើយ គេបដិសេធព្រះបន្ទូល។ គឺជាព្រះបន្ទូលដែលនៅខាងក្រៅមិនអាចចូលមកក្នុងបាន។

144 ឥឡូវស្ត្រីម្នាក់នេះជាអ្នកថ្មីសម្រាប់ខ្ញុំ។ ខ្ញុំមិនធ្លាប់ជួបគាត់ពីមុនទេក្នុងជីវិតរបស់ខ្ញុំ។ ព្រះជាម្ចាស់ជាអង្គប្រោសឱ្យជា។ វាមិនមែនសម្រាប់ការប្រោសឱ្យជា វាអាចជាសម្រាប់អ្វីផ្សេងទៀត បើសិនជាព្រះជាម្ចាស់ពន្យល់មកខ្ញុំពីបញ្ហារបស់អ្នក តើអ្នកជឿខ្ញុំឬទេ? រឿងទីមួយដែលអ្នកចង់អធិស្ឋានគឺ អ្នកមានបញ្ហាត្រចៀក។ ត្រចៀកម្ខាងរបសស់អ្នកមិនអាចស្តាប់ឮទេ។ នោះគឺត្រូវហើយ។ ជាការពិត។ ហើយអ្នកមានទម្លាប់មួយ អ្នកចង់បំបាត់ទម្លាប់នោះ គឺជក់បារី។ ដាក់ម្រាមដៃក្នុងត្រចៀកល្អរបស់អ្នកត្រូវហើយ គឺដាក់លើត្រចៀកដែលមិនឈឺ។ ត្រូវហើយ។ ឥឡូវ សូមជឿដល់ព្រះជាម្ចាស់ ហើយដើរទៅត្រលប់ទៅវិញចុះ ហើយកុំ...ហើយអ្នកនឹងមិនជក់បារីទៀតឡើយបើអ្នកជឿ។ ទៅចុះសូមព្រះប្រទានពរ។

ចាំមើលអ្វីដែលកើតឡើង តើព្រះអង្គមានពិតឬទេ?

145 ខ្ញុំមិនស្គាល់អ្នកទេ យើងសុទ្ធតែជាអ្នកថ្មីចំពោះគ្នា។ ខ្ញុំមិនធ្លាប់ជួបអ្នកក្នុងជីវិតខ្ញុំឡើយ ប៉ុន្តែព្រះជាម្ចាស់ព្រះអង្គស្គាល់អ្នក។ បើព្រះជាម្ចាស់អាចប្រាប់ខ្ញុំពីអ្វីមួយអំពីអ្នក តើអ្នកជឿទេ?

146 តើអ្នកចូលរួមទាំងអស់ជឿឬទេ? តើមាននរណាម្នាក់ស្គាល់ស្ត្រីនេះទេ? តើមាននរណាម្នាក់ក្នុងចំណោមអ្នកចូលរួមស្គាល់ស្ត្រីនេះទេ?ត្រូវហើយអ្នកដឹងហើយថានេះជាការពិតឬអត់។ រឿងនេះគួរដោះស្រាយ។ នេះត្រូវប្រាប់ពីសេចក្ដីពិត។

147 ឥឡូវអ្នកអាចឃើញអ្វីដែលកើតឡើងនៅប៉ុន្មាននាទីចុងក្រោយនេះ។ ឃើញទេ? វាទើបតែ...ខ្ញុំទ្រេតទ្រូត។ ឃើញទេ? គ្រប់យ៉ាងក្លាយជាសេចក្ដីងងឹតសម្រាប់ខ្ញុំ។ ឃើញទេ វាជាការដឹង។ ឃើញទេ គឺជាព្រះវិញ្ញាណបរិសុទ្ធ។ មិនមែនជាខ្ញុំឡើយ។ គឺ ព្រះបន្ទូលសន្យាសម្រាប់សម័យនេះ។ វាមិនមានតាំងពីសម័យសាវ័ក វាមិនធ្លាប់មានឡើយ។ ប៉ុន្តែធ្លាប់មានកន្លែងដែលនិយាយ "មុនពេលដែលបុត្រមនុស្សយាងមក។ វាក៏ដូចជាសម័យឡុតដែរ ការយាងមករបស់បុត្រមនុស្សក៏ដូចគ្នាដែរ។" អ្នកមិនជឿមិនជឿនោះឡើយ។ ពួកគេមិនរំពឹងថានឹងជឿឡើយ។ ប៉ុន្តែអ្នកជឿជឿសេចក្ដីនោះ!

148 ឥឡូវ បើសិនជាព្រះវិញ្ញាណបរិសុទ្ធបើកសម្ដែងការនេះ តើប៉ុន្មាននាក់ដែលជឿអស់ពីចិត្ត សូមលើកដៃរបស់អ្នក?

149 អ្នកមានការបាក់ខ្នងខ្លាំ។ អ្នកមានគ្រោះថ្នាក់ជាមួយនឹងឡាន វាទាញឆ្អឹងខ្នងរលាចេញពីក។ អ្នកក៏មានការចុះខ្សោយតម្រងនោមដែរ។ នោះគឺត្រូវហើយមែន ទេ? អ្នកជឿទេ? [ស្ត្រីនិយាយថា "ចាស"—Ed]តើអ្នកជឿទេ?["ចាស ហ្នឹងហើយ"]អ្នកនឹងជាវិញ។ សូមសរសើរព្រះអម្ចាស់។

150 អ្នកជឿថាព្រះជាម្ចាស់ព្យាបាលជំងឺបញ្ហាតម្រងនោមរបស់អ្នកមែនទេ? ដូច្នេះទៅចុះហើយទទួលការប្រោសឱ្យជារបស់អ្នកចុះ។

151 ចូលមក ស្ត្រីអើយ។ មើលតាមនេះ។ អ្នកជឿថាព្រះជាម្ចាស់ប្រោសបញ្ហាបេះដូងឱ្យជាឬទេ? ត្រូវហើយ ទៅតាមផ្លូវរបស់អ្នកហើយជឿចុះ បេះដូងរបស់អ្នកនឹងបានជា។

152 សូមមកទីនេះ។ អ្នកជឿថាព្រះជាម្ចាស់អាចព្យាបាលខ្នងរបស់អ្នកទេ ប្រោសអ្នកឱ្យបានជា?ចូរចេញទៅ ហើយ ជឿចុះ។

គ្រាន់តែជឿព្រះជាម្ចាស់ប៉ុណ្ណោះ នោះជាអ្វីដែលអ្នកត្រូវធ្វើ!

153 ចូលមកស្ត្រីទាំងឡាយអើយ។ តើអ្នកជឿថាព្រះជាម្ចាស់អាចប្រោសជំងឺក្រពះ ឱ្យជាឬទេ? ទៅចុះបរិភោគអាហារពេលល្ងាចរបស់អ្នកជឿអស់ពីចិត្តរបស់អ្នកចុះ។

154 ចូលមក។អ្នកជឿថាព្រះជាម្ចាស់អាចប្រោសជំងឺឈឺសន្លាក់ឱ្យជាឬទេ? ដូច្នេះ ចូរចេញទៅជឿហើយ...ហើយព្រះជាម្ចាស់នឹងប្រោសអ្នកឱ្យជា។

155 ត្រូវហើយ ចូលមក។ អ្នកជឿអស់ពីចិត្តទេ? អ្នកជឿទេ? ជំងឺឈឺសន្លាក់ទៀតហើយ។ តើអ្នកជឿថាព្រះជាម្ចាស់ អាចធ្វើឱ្យអ្នកជឿឬទេ? ចូរទៅចុះ ជឿចុះ និយាយថា "អរព្រះគុណព្រះជាម្ចាស់។"

តើប៉ុន្មាននាក់ដែលជឿ? តើអ្នកជឿទេ?

156 ស្ត្រីម្នាក់នេះដែលស្លៀករ៉ូបពណ៌ក្រហម លើកដៃរបស់នាង គាត់មានបញ្ហាលើសឈាម។ តើអ្នកជឿព្រះជាម្ចាស់ ថាអាចប្រោសអ្នកឱ្យជាឬទេ? ជឿទេ? ត្រូវណាស់។ សូមដាក់ដៃលើស្ត្រីដែលនៅក្បែរអ្នក ហើយប្រាប់គាត់ថា សម្លេងរបស់គាត់នឹងប្រសើរឡើងវិញ។ អាម៉ែន។

គឺពិតមែន។ អាម៉ែន។ តើអ្នកជឿទេ? ចូរមានជំនឿចុះ!

157 មានមនុស្សម្នាក់អង្គុយនៅទីនេះ មានបញ្ហាចេញឈាម។ តើលោកជឿទេ លោកដែលអង្គុយនៅទីនេះ? បាទ គឺអ្នកមានជំងឺចេញឈាម។ តើអ្នកជឿថានឹងបានជាទេ?

158 ស្ត្រីនៅក្បែរអ្នកក៏មានជំងឺចេញឈាមដែរ ហើយគាត់ក៏មានបញ្ហាឈឺខ្នងដែរ។ តើអ្នកជឿថាព្រះជាម្ចាស់នឹងប្រោសអ្នកឱ្យជាឬទេ? ជឿទេ? សូមលើកដៃហើយទទួលចុះ។ សូមជឿចុះ។

159 ស្ត្រីម្នាក់នេះដែលនៅក្បែរអ្នកមានបញ្ហាជើងនិងត្រគាក។ តើអ្នកជឿថានឹងជាទេ អ្នកស្រី? តើអ្នកជឿថាអ្នកនឹងបានជាឬទេ? បាទ លើកដៃអ្នកឡើង និយាយ "ខ្ញុំទទួល។"

160 ល្អហើយ ស្ត្រីដែលនៅជិតនោះ គាត់មានជំងឺឆ្លង។ តើអ្នកជឿថាព្រះជាម្ចាស់នឹងប្រោសជំងឺឆ្លងឱ្យជាឬទេ អ្នកនាងម្នាក់វ័យក្មេង ពាក់វ៉ែនតានៅទីនោះ? សូមលើកដៃឡើង និយាយ "ខ្ញុំទទួល។" ត្រូវហើយ ជឿចុះ។

161 ស្ត្រីដែលនៅក្បែរនាង មានបញ្ហាតម្រងនោម។ តើអ្នកជឿថាព្រះជាម្ចាស់អាច ប្រោសជំងឺតម្រងនោមឱ្យជាឬទេ អ្នកនាង? ត្រូវហើយ សូមលើកដៃហើយទទួលចុះ។

162 អ្នកនាងក្មេងម្នាក់ដែលនៅក្បែរគាត់ គឺមានជំងឺពកក។ តើអ្នកជឿថាព្រះជាម្ចាស់អាចប្រោសជំងឺពកកឱ្យជាទេ? សូមលើកដៃហើយទទួលចុះ។

163 តើមានប៉ុន្មាន នាក់ដែលជឿអស់ពីចិត្តរបស់អ្នក? ដូច្នេះ សូមក្រោកឈរហើយទទួលចុះ។ សូមក្រោកឡើងក្នុងវត្តមានរបស់ព្រះជាម្ចាស់នៃអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប។

164 ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត សូមឱ្យព្រះវិញ្ញាណបរិសុទ្ធចាក់បង្ហូរមកក្នុងអាគារនេះឥឡូវ និងប្រោសមនុស្សគ្រប់គ្នាឱ្យបានជាដោយព្រះវត្តមាននៃព្រះជាម្ចាស់!

## ព្រះជាម្ចាស់ជាអ្នកបកស្រាយសម្រាប់ព្រះអង្គផ្ទាល់ KHM64-0205

(God Is His Own Interpreter)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាចថ្ងៃពុធ ថ្ងៃទី 5 កុម្ភៈ 1964 នៅ Kern County Fairgrounds, Bakersfield, California, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2019 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

# ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG